ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ឋានទូតកម្ពុជាប្រជាធិបតេយ្យៈ រូបថតក្នុងខែសីហា ឆ្នាំ១៩៧៨

◆ សេចក្ដីថ្លែងការណ៍ពីរដ្ឋមន្ត្រីក្រសួងការបរទេស អៀង សារី

រូបថតៈ ហ្គុនណា បឺយស្រ្តម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខពិសេស ១០៧ ខែវិច្ឆិកា ឆ្នាំ២០០៨

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខពិសេស ១០៧ ខែវិច្ឆិកា ឆ្នាំ២០០៨

## មាតិកា


◆ ឋានទេរកកម្ពុជាប្រជាធិបតេយ្យ ........................................................១
◆ ការកាត់ទោសតាមផ្លូវច្បាប់អាចបន្ធូរបន្ថយកំហឹងរបស់ប្រជាជន ..............៥
◆ សេចក្តីថ្លែងការណ៍ពីរដ្ឋមន្ត្រីក្រសួងការបរទេស អៀង សារី ...................៦
◆ របាយការណ៍វេទិកាពិភាក្សាតាមភូមិនៅស្រុកបាធាយ ........................១០
◆ រួចពីស្លាប់ដោយសារធ្មើល្អ ...........................................................១៣
◆ អតីតកាលរបស់ខ្ញុំ ......................................................................៦០




អ្នកផលិតឱសថ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



រទេះសេះ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា


***ស្នេរលេខនេះ*** ៖ *សារ៉ា ចូន ឌីកកិន, ស៊ីរ៉ៃ សាវីណា, ហ៊ិន សុធានី, ជា វិបុល* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *គាត លក្ខិណា, សោម ប៊ុនថន* ***អ្នកបកប្រែ***៖ *ជា ផល្លា* ***និពន្ធនាយកទូទៅ***៖ *ឆាំង យុ* ***ជំនួយការនិពន្ធនាយក***៖ *ទេព ម៉េងឃាន* ***ក្រាហ្វិកកុំព្យូទ័រ***៖ *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយ***៖ *ផេង ពង*


Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ឋាននរកកម្ពុជាប្រជាធិបតេយ្យៈ រូបថតក្នុងខែសីហា ឆ្នាំ១៩៧៨
# ពិព័រណ៍រូបថតនិងសិក្ខាសាលាជាមួយ ហ្គុនណា ប៊ឺយស្ត្រម

ហ្គុនណា ប៊ឺយស្ត្រម មិនដែលវិលត្រឡប់មកមើលប្រទេសកម្ពុជាទាល់តែសោះ ចាប់តាំងពីដំណើរទស្សនកិច្ចរបស់គាត់កាលពីសាមសិបឆ្នាំមុន ។ ក្នុងឆ្នាំ១៩៧៨ ហ្គុនណា បានស្នាក់នៅប្រទេសកម្ពុជាក្នុងរយៈពេល១៤ថ្ងៃជាមួយនឹងតំណាងផ្សេងទៀតរបស់សមាគមមិត្តភាពស៊ុយអែដ-កម្ពុជានៅក្នុងដំណើរទស្សនកិច្ចការទូតមួយដែលខ្មែរក្រហមមានបំណងប្រើប្រាស់ដើម្បីទាក់ទាញការគាំទ្រពីបណ្តាប្រទេសកុម្មុយនីស្តដទៃទៀត ។ នៅអំឡុងទស្សនកិច្ចនេះ គណៈប្រតិភូត្រូវបានកម្មាភិបាលខ្មែរក្រហមនាំទស្សនាទីកន្លែងជាច្រើននៅទីក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ចាម កំពង់ធំ សៀមរាប កំពត និងក្រុងកំពង់សោម ។ ហ្គុនណា បានទៅមើលមន្ទីរពេទ្យ រោងចក្រ សាលារៀន និងប្រជាជនកំពុងធ្វើការងារនៅតាមវាលស្រែ ការដ្ឋានជីកប្រឡាយនិងនៅកន្លែងផ្សេងៗទៀត ។ គាត់ថែមទាំងបានទទួលទានអាហារពេលល្ងាចជាមួយ ប៉ុល ពត និង អៀង សារី ដែលជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផង ។ ខណៈពេលដែលគណៈប្រតិភូស៊ុយអែដកំពុងតែទទួលទានអាហារនិងជល់កែវស្រាជាមួយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប្រទេសកម្ពុជាទាំងមូលកំពុងតែស្ថិតនៅក្នុងសភាពខ្ទេចខ្ទាំ÷ ប្រជាជនកម្ពុជាកំពុងតែស្លាប់ បាក់កម្លាំង ស្រេកឃ្លាន និងខំប្រឹងសម្របខ្លួនដើម្បីរស់នៅក្នុងប្រទេសដែលកំពុងតែវិនាសហិនហោច ។ ក្រោយពេលវិលត្រឡប់ទៅប្រទេសស៊ុយអែដវិញ គណៈប្រតិភូបានលើកសរសើរអំពីកម្ពុជាថាជាបដិវត្តន៍គំរូមួយ បើទោះបីជាទើបនឹងចាប់ផ្តើមនិងមិនទាន់ល្អឥតខ្ចោះក៏ដោយ ។ ជាងនេះទៅទៀត គណៈប្រតិភូថែមទាំងបង្ហាញឲ្យឃើញជំនឿដ៏មុតមាំថារបបកុម្មុយនីស្តអាចជាជម្រើសដ៏ល្អបំផុតសម្រាប់ប្រជាជនកម្ពុជា ។ រហូតដល់ពេលដែលបានឃើញជនភៀសខ្លួនកម្ពុជារាប់ម៉ឺននាក់ភៀសខ្លួនចូលទៅក្នុងទឹកដីថៃ ទើបគណៈប្រតិភូដឹងថា ខ្លួនបានយល់ខុសទាំងស្រុងចំពោះបដិវត្តន៍កម្ពុជា ។ នៅក្នុងអំឡុងទស្សនកិច្ច ហ្គុនណា និងមិត្តរួមដំណើររបស់គាត់បានថតរូបភាពនិងភាពយន្តឯកសារនៅទីកន្លែងមួយចំនួនដែលគាត់បានទៅដល់ ។ បច្ចុប្បន្ន ខ្សែភាពយន្តឯកសារនោះកំពុងស្ថិតនៅក្រោមការថែរក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។



ហ្គុនណា ប៊ឺយស្ត្រម ឆ្នាំ១៩៧៨

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ខាងមុខនេះ ហ្គុនណា នឹងវិលត្រឡប់មកប្រទេសកម្ពុជាជាថ្មីម្តងទៀតនិងជាលើកទីមួយ បន្ទាប់ពីទស្សនកិច្ចរបស់គាត់កាលពីឆ្នាំ១៩៧៨ ។ គាត់នឹងជួបសន្ទនា និងពិភាក្សាជាមួយមេឃុំចំនួន៨៥០នាក់និងប្រជាជននៅតាមភូមិឃុំ ព្រមទាំងនិយាយប្រាប់ប្រជាជនកម្ពុជានិងពិភពលោកអំពីអ្វីដែលគាត់បានឃើញ បានធ្វើ មិនដឹងមិនឮ និងអ្វីដែលគាត់មិនបានឃើញទាល់តែសោះនៅក្នុងពេលទស្សនកិច្ច ។ ជាមួយនឹងការវិលត្រឡប់មកប្រទេសកម្ពុជាជាថ្មីម្តងទៀតរបស់ ហ្គុនណា ប៊ឺយស្ត្រម មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយវេទិកាប្រវត្តិសាស្ត្ររស់នៅប្រទេសស៊ុយអែដ បានរៀបចំការតាំងពិព័រណ៍រូបថតមួយដែលមានចំណងជើងថា «នរកកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨» ។ រូបថតដែលប្រើប្រាស់នៅក្នុងពិព័រណ៍នេះជារូបថតដែលថតដោយ ហ្គុនណា និងមិត្តរួមដំណើររបស់គាត់ក្នុងអំឡុងពេលទស្សនកិច្ចកាលពីឆ្នាំ១៩៧៨ និងដែលយើងមិនធ្លាប់បានឃើញពីមុនមក ។ វាគឺជារូបពណ៌ធម្មជាតិដ៏ស្រស់

ស្អាត ផ្ទុយពីរូបថតភាគច្រើនដែលថតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យជារូបស-ខ្មៅ ។ ពិព័រណ៍នេះនឹងចាប់ផ្តើមបើកបង្ហាញសាធារណជននៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅវិទ្យាស្ថានវ៉ៃយំ នៅរាជធានីភ្នំពេញ ព្រមទាំងសិក្ខាសាលាមួយនៅវិទ្យាស្ថានជាតិអប់រំដែលមាន ហ៊ុនណា ប៊ីយស្រួម ជាវាគ្មិនពិសេស ។ ពិព័រណ៍នេះក៏នឹងមានដាក់តាំងនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង នៅទីស្នាក់ការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បន្ទាប់មកនឹងធ្វើដំណើរទៅខេត្តកំពង់ចាម តាកែវ និងបាត់ដំបង ។ ពិព័រណ៍ដូចគ្នានេះក៏នឹងបើកបង្ហាញនៅទីស្នាក់ការវេទិកាប្រវត្តិសាស្ត្ររស់ ក្នុងទីក្រុងស្តុកខូម ប្រទេសស៊ុយអែដដែរនៅក្នុងរដូវក្តៅឆ្នាំ២០០៩ និងធ្វើដំណើរជុំវិញប្រទេសស៊ុយអែដចាប់ពីដើមឆ្នាំ២០១០ ។

«ឋាននរកកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨» នឹងប្រាប់រឿងរ៉ាវតាមរយៈម៉ាស៊ីនថតរូបរបស់ ហ៊ុនណា ដែលបានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៨ ។ វាគួរឲ្យចម្លែកបន្តិចត្រង់ថា រូបថតមួយចំនួននៅក្នុងពិព័រណ៍នេះបង្ហាញឲ្យឃើញទីក្រុងភ្នំពេញដែលស្ងាត់ជ្រងំ ព្រះបរមរាជវាំង ប្រាសាទអង្គរវត្ត និង ហ៊ុនណា ព្រមទាំងសមាជិកដទៃទៀតនៃគណៈប្រតិភូដែលមានទឹកមុខញញឹមរីករាយក្នុងឱកាសសន្ទនាជាមួយកម្មាភិបាលខ្មែរក្រហមនៅជនបទ ។ រូបថតមួយចំនួនទៀតបង្ហាញឲ្យឃើញពីស្ថានភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនដែលក្រឡេកមួយភ្លែតទៅធ្វើឲ្យយើងជឿជាក់ថាល្អពិតមែនគឺការទទួលទានអាហាររួម ការធ្វើការងារនៅវាលស្រែ ការលើកទំនប់និងជីក




ប្រឡាយ ។ ដូចជាឯកសារជាច្រើនទៀតដែលសរសេរឡើងដោយរបបខ្មែរក្រហម រូបថតរបស់ ហ៊ុនណា មិនបានបង្ហាញឲ្យឃើញទារុណកម្ម ភាពស្រេកឃ្លាន ការស្លាប់រង្គាល និងការបាក់ទឹកចិត្តដែលគ្រប់គ្នាល្បីអំពីខ្មែរក្រហមនោះឡើយ ។ កង្វះខាតនេះបង្កើតឲ្យមានសំណួរថាតើអ្វីទៅជាមូលហេតុនៃការគាំទ្ររបស់គណៈប្រតិភូស៊ុយអែដចំពោះខ្មែរក្រហម? តើកម្មាភិបាលខ្មែរក្រហមបានរៀបចំទុកជាមុននូវអ្វីៗដែលគណៈប្រតិភូបានឃើញ ឬក៏គណៈប្រតិភូខ្លួនឯងមានចេតនាជឿទាំងងងឹតងងល់ចំពោះស្ថានភាពដែលនៅជុំវិញខ្លួន? តើគណៈប្រតិភូស៊ុយអែដគឺជាអ្នកឈរឱបដៃមើលឬក៏ជាជនរងគ្រោះដែលត្រូវខ្មែរក្រហមបោកប្រាស់ដែរ?

យើងសង្ឃឹមថា ពិព័រណ៍នេះនឹងផ្តល់ពន្លឺខ្លះដល់ដំណើរទស្សនកិច្ចកាលពីឆ្នាំ១៩៧៨ ផ្តល់ចំណេះដឹង និងបង្កើតការពិភាក្សាអំពីតួនាទីរបស់សហគមន៍អន្តរជាតិក្នុងការចូលរួមចំណែកឬមិនចូលរួមចំណែកពីអតីតកាលនិងបច្ចុប្បន្នកាល ។ យើងក៏សង្ឃឹមថា ពិព័រណ៍និងសិក្ខាសាលានេះនឹងលើកទឹកចិត្តឲ្យសមាជិកដទៃទៀតនៃគណៈប្រតិភូស៊ុយអែដដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៨ ចេញមកចែករំលែកជាមួយពិភពលោកនូវរឿងរ៉ាវបទពិសោធន៍ និងឯកសាររបស់ខ្លួន ។ សំខាន់ជាងនេះទៅទៀត ពិព័រណ៍នេះប្រហែលជានាំមកនូវការផ្សះផ្សាសម្រាប់ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលនៅរស់រានមានជីវិតមកដល់បច្ចុប្បន្ន ដែលមានចម្ងល់អស់រយៈពេលសាមសិបឆ្នាំថា គណៈប្រតិភូបរទេសដែលមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ហេតុអ្វីក៏មិនជួយសង្គ្រោះប្រជាជនកម្ពុជា? ខណៈដែលតុលាការខ្មែរក្រហមប្រហែលជាអាចត្រួសត្រាយផ្លូវសម្រាប់ដំណើរការផ្សះផ្សាសង្គមកម្ពុជាទាំងមូល ការចូលរួមចំណែករបស់បុគ្គលម្នាក់ៗនៅក្នុងដំណើរការនេះមានសារសំខាន់ណាស់ មិនថាបុគ្គលនោះជាជនរងគ្រោះ ជាអតីតជនដៃដល់ ឬជាអ្នកឈរឱបដៃមើលទេ ទោះបីជាអ្នកទាំងនោះមានចេតនាចូលរួមចំណែកឬត្រូវបានបង្ខំឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបានគាំទ្រផ្នែកស្មារតី ឬនៅស្ងៀមមិនបញ្ចេញប្រតិកម្មអ្វីទាំងអស់ក៏ដោយ ។ ចំណុចចុងក្រោយនេះអាចជាមូលហេតុសំខាន់បំផុតដែល ហ៊ុនណា វិលត្រឡប់មកប្រទេសកម្ពុជាជាថ្មីម្តងទៀត ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ហ៊ុនណា បឺយស្រ្តម ជាអ្នកណា?

ក្នុងឆ្នាំ១៩៧៨ លោក ហ៊ុនណា បឺយស្រ្តម មានអាយុ២៧ ឆ្នាំ និងមានកូនពីរនាក់ ។ ហ៊ុនណា បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងចលនាប្រឆាំងនឹងសង្រ្គាមនៅវៀតណាម ឡាវ និងកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំ ។ នៅប្រទេសស៊ុយអែដ ចលនានេះមានសកម្មភាពខ្លាំងក្លា អាចថាខ្លាំងជាងបណ្តាប្រទេសណាៗទាំងអស់នៅលោកខាងលិច ។ យុវជនរាប់ពាន់នាក់លះបង់ពេលវេលាទាំងអស់របស់ខ្លួនធ្វើការងារដើម្បីប្រឆាំងនឹងសង្រ្គាមអាមេរិក ។ ហ៊ុនណា នៅក្នុងចំណោមយុវជនទាំងនោះ ។ ហ៊ុនណា លះបង់យុវវ័យទាំងអស់របស់គាត់ដើម្បីបុព្វហេតុតែមួយនេះ ។

ក្រោយមកទៀត ហ៊ុនណា ក៏ដូចជាអ្នកដទៃទៀតត្រូវបានទាក់ទាញដោយទស្សនវិជ្ជាកុម្មុយនីស្តម៉ៅនិយម ។ យើងជឿជាក់ថាបដិវត្តន៍សហភាពសូវៀតមិនទាន់បរិសុទ្ធនៅឡើយ ហើយបដិវត្តន៍ចិនក៏ខុសប្លែកពីគ្នា ។ មនុស្សមួយចំនួនចាប់អារម្មណ៍ចំពោះបដិវត្តន៍កម្ពុជាដែលយើងយល់ថាថ្មី និងបរិសុទ្ធ ហើយការចាប់អារម្មណ៍នេះចេះតែកើនឡើង ។

ហ៊ុនណា គឺជាសមាជិកបក្សម៉ៅនិយមនោះរហូតដល់ឆ្នាំ ១៩៧៩ ទើបចាកចេញ ហើយចាប់ផ្តើមបើកចំហជាសាធារណៈនូវគំនិតដែលផ្ទុយពីការយល់ឃើញពីពេលមុនរបស់គាត់ ពីព្រោះតែគាត់យល់ថាយើងបានយល់ខុសតាំងពីដើមមក ។

បច្ចុប្បន្ន ហ៊ុនណា អាយុ៥៧ឆ្នាំ និងធ្វើការងារជាទីប្រឹក្សាកែតម្រង់ផ្លូវអ្នកដែលញៀនថ្នាំនិងធ្លាប់ប្រព្រឹត្តបទឧក្រិដ្ឋ ។ ហ៊ុនណា រស់នៅជាមួយប្រពន្ធរបស់គាត់នៅ វិលិនធូណា ភាគខាងជើងទីក្រុងស្តុកខូម ។ កូនៗទាំងប្រាំនាក់របស់គាត់ធំពេញវ័យ និងបានបែកផ្ទះរៀងៗខ្លួន ។

ហ៊ុនណា លែងជាមនុស្សសកម្មនៅក្នុងគណបក្សនយោបាយទៀតហើយ ព្រោះគាត់មិនឃើញមានគណបក្សណាមួយដែលពេញចិត្តសោះ ។ គាត់នៅតែជឿជាក់ថា យើងអាចបង្កើតពិភពលោកមួយដែលស្មើភាពនិងយុត្តិធម៌ ក៏ប៉ុន្តែគាត់មិនជឿទៅលើដំណោះស្រាយតាមបែបម៉ៅនិយមដែលគាត់ធ្លាប់បានជឿកាលពីឆ្នាំ១៩៧៨ឡើយ ។

# ដំណើរកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨

ហ៊ុនណា បានទៅធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាពីថ្ងៃទី១២ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៧៨ ។ នៅពេលនោះប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម និងមានឈ្មោះជាផ្លូវការថា «កម្ពុជាប្រជាធិបតេយ្យ» ។ ប៉ុល ពត គឺជានាយករដ្ឋមន្ត្រី ។ គណៈប្រតិភូរបស់យើងដែលមានសមាជិកបួននាក់មានប្រភពមកពី«សមាគមមិត្តភាពស៊ុយអែដ-កម្ពុជា» ។ យើងស្ថិតនៅក្នុងចំណោមគណៈប្រតិភូដែលធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យជាលើកដំបូងបំផុតចាប់តាំងពីខ្មែរក្រហមឡើងកាន់អំណាច ។

កាលពីពេលនោះ ហ៊ុនណា គឺជាអ្នកគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យ ។ ឥឡូវនេះពេលដែល ហ៊ុនណា មានការយល់ដឹងប្រសើរជាងមុន គាត់មើលទៅសាមសិបឆ្នាំក្រោយវិញ និងខំប្រឹងស្វែងយល់អំពីដំណើរទស្សកិច្ច នៅពេលនោះគាត់យល់ឃើញថាកាលនោះយើងមិនគួរធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យទាល់តែសោះ ពីព្រោះនោះជាផ្នែកមួយនៃការឃោសនានយោបាយរបស់ខ្មែរក្រហម ។ ហ៊ុនណា មានអារម្មណ៍សោកស្តាយខ្លាំងណាស់ដែលបានចូលរួមក្នុងដំណើរទស្សកិច្ចនោះ ក៏ប៉ុន្តែខ្ញុំមិនអាចត្រឡប់ក្រោយវិញបានទេ ។ ហ៊ុនណា អាចព្យាយាមរៀនសូត្រអំពីបទពិសោធន៍នោះ ។ ហ៊ុនណា សង្ឃឹមថាពិព័រណ៍អំពីរូបថតដែលយើងបានថតកាលពីពេលនោះជាមួយនឹងការពិព័រណ៌នាអំពីការយល់ឃើញរបស់គាត់ គួបផ្សំនឹងការឆ្លុះបញ្ចាំងរបស់សាធារណជននឹងបង្កើតឲ្យមានការយល់ដឹងប្រសើរជាងមុនអំពីរបបខ្មែរក្រហម ។ ជាងនេះទៅទៀត ពិព័រណ៌នេះនឹងបង្ហាញអំពីរបៀបដែលមនោគមន៍វិជ្ជាបោកប្រាស់អាចធ្វើឲ្យមនុស្សជឿងប់ងុល សូម្បីតែគាត់ក៏ជឿថាខ្លួនឯងកំពុងតែប្រយុទ្ធដើម្បីបុព្វហេតុដ៏ត្រឹមត្រូវ ។

ហ៊ុនណា ធ្លាប់បានធ្វើការនៅក្នុងចលនាប្រឆាំងនឹងសង្រ្គាមនៅក្នុងប្រទេសកម្ពុជានិងវៀតណាមនៅអំឡុងទសវត្សរ៍៧០ ។ នៅក្នុងរបបខ្មែរក្រហម យើងគិតថាយើងបានឃើញបដិវត្តន៍ដ៏បរិសុទ្ធមួយដែលមិនស្ថិតនៅក្រោមឥទ្ធិពលរបស់មហាអំណាចបរទេស ។ ខ្លួនគាត់ផ្ទាល់ក៏ដូចជាប្រជាជនស៊ុយអែដមួយចំនួននៅក្នុងជំនាន់របស់គាត់បានទទួលស្គាល់បដិវត្តន៍ចិនរបស់ ម៉ៅ សេទុង

ប៉ុន្តែនៅពេលដែលយើងបានអានអំពីបដិវត្តន៍កម្ពុជាយើងយល់ថា យើងបានរកឃើញបដិវត្តន៍មួយដែលប្រសើរជាងបដិវត្តន៍របស់ចិនទៅទៀត គឺជាបដិវត្តន៍មួយដែលស្មើភាព គ្មានការគាបសង្កត់ គ្មានទាសភាព និងដែលព្យាយាមចៀសវាងកំហុសឆ្គងដែលបដិវត្តន៍កុម្មុយនីស្តពីមុនៗធ្លាប់ឆ្លងកាត់ ។

មួយរយៈក្រោយមក យើងបានស្តាប់និងអានរឿងរ៉ាវអំពីការសម្លាប់និងការគាបសង្កត់ ។ យើងមិនចង់ជឿទាល់តែសោះ ។ ប្រហែលជាមានរឿងរ៉ាវមួយចំនួនជាការពិត ក៏ប៉ុន្តែយើងអាចដោះសាថា នោះបណ្តាលមកពីភាពច្របូកច្របល់ក្រោយពីសង្គ្រាម ។ មិនយូរទេ កម្ពុជានឹងធ្វើឲ្យសុបិនក្លាយជាការពិតនូវបដិវត្តន៍មួយដែលគួរឲ្យស្ងើចសរសើរនិងខុសពីបដិវត្តន៍ដទៃទៀត ។

ឥឡូវនេះ ហ្គុនណា ទើបតែដឹងថា សូម្បីតែនៅមុនដំណើរទស្សនកិច្ចរបស់យើង មានភស្តុតាងជាច្រើនដែលបញ្ជាក់ការពិតនៅប្រទេសកម្ពុជាអំពីការសម្លាប់ ការគាបសង្កត់ និងការធ្វើទារុណកម្ម ប៉ុន្តែយើងមិនជឿ ។ បន្ទាប់មកយើងត្រូវបានអញ្ជើញទៅប្រទេសកម្ពុជាដើម្បីមើលដោយផ្ទាល់ភ្នែក ។ រូបថតទាំងប៉ុន្មានដែលអ្នកទាំងអស់គ្នាកំពុងតែមើលនេះគឺជាអ្វីដែលយើងបានឃើញ ។ ជាការពិតណាស់ដែលយើងមិនបានទៅឃើញគុកទួលស្លែងដែលខ្មែរក្រហមរក្សាជាសម្ងាត់និងមិនបានឃើញអំពើសាហាវឃោរឃៅ ។ យើងមិនចេះភាសាខ្មែរ យើងពឹងផ្អែកតែទៅលើមគ្គុទ្ទេសក៍ខ្មែរក្រហម ដែលមិនអនុញ្ញាតឲ្យយើងសម្រាកពេលយប់នៅឯសហករណ៍ ក៏ប៉ុន្តែរូបភាពទាំងនេះគួបផ្សំនឹងទស្សនៈមនោគមវិជ្ជារបស់យើង ធ្វើឲ្យយើងមើលឃើញតែអ្វីដែលយើងចង់ឃើញ ។ នៅក្នុងពិព័រណ៍នេះ លោកអ្នកនឹងឃើញដំណើរទស្សនកិច្ចរបស់យើង ឃើញអ្វីដែលយើងបានឃើញនិងឆ្លុះបញ្ចាំងការយល់ឃើញរបស់ ហ្គុនណា ពីពេលនោះនិងពេលបច្ចុប្បន្ន ។

យើងត្រូវតែរៀនសូត្រពីបទពិសោធន៍ប្រវត្តិសាស្ត្រទើបរឿងរ៉ាវដូចគ្នានេះមិនកើតឡើងជាថ្មីម្តងទៀត ។ **ហ្គុនណា បឺយស្ត្រម**



ធាក់រហាត់នាំទឹកបញ្ចូលស្រែ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

# ការកាត់ទោសតាមផ្លូវច្បាប់អាចបន្ធូរបន្ថយកំហឹងរបស់ប្រជាជន

*នៅថ្ងៃសុក្រទី១៧ ខែតុលា ឆ្នាំ២០០៨ តុលាការខ្មែរក្រហមបានបដិសេធបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំរបស់អតីតមន្ត្រីក្រសួងការបរទេសរបស់ខ្មែរក្រហមដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។*

*អ្នកភូមិ៥០នាក់ មកពីខេត្តកំពង់ស្ពឺ កណ្តាល និងកំពត បានជួបជុំគ្នាដើម្បីស្តាប់សវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹង អៀង សារី និងសេចក្តីសម្រេចដែលមានរយៈពេលយូរ ។*

*តោ សុផល ស្ត្រីម្នាក់មកពីខេត្តកំពង់ស្ពឺដែលបានបាត់បង់ប្អូនៗពីរនាក់នៅក្នុងរបបខ្មែរក្រហមចង់ដឹងថាហេតុអ្វីបានជាមានអំពើឃោរឃៅទាំងនោះកើតឡើង ហើយតើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការស្លាប់របស់សមាជិកគ្រួសាររបស់នាង ។*

*នៅថ្ងៃនោះ តោ សុផល និងប្រជាជនដទៃទៀតពិតជាចង់ដឹងថាតើ អៀង សារី នឹងត្រូវឃុំខ្លួនឬក៏ដោះលែង ។*

*អៀង សារី អាយុ៨២ឆ្នាំ គឺជាសមាជិកម្នាក់ក្នុងចំណោមអ្នកដឹកនាំរបបកុម្មុយនីស្តដែលត្រូវទទួលខុសត្រូវចំពោះប្រជាជនប្រហែល១.៧លាននាក់ដែលបានស្លាប់ដោយសារការសម្លាប់ទារុណកម្ម ភាពអត់ឃ្លាន និងការបង្ខំឲ្យធ្វើការធ្ងន់ ។*

*តោ សុផល ក៏ដូចជាប្រជាជនរាប់លាននាក់ផ្សេងទៀតដែរ គាត់ត្រូវបានជម្លៀសចេញពីផ្ទះ និងបង្ខំឲ្យធ្វើការធ្ងន់នៅជំរំពលកម្មដោយឲ្យជីកប្រឡាយ និងព្រែក រហូតដល់យប់ ។ របបអាហាររបស់គាត់មានត្រឹមតែបបររាវ៣វែកក្នុងមួយថ្ងៃ ។ សុផល រៀបរាប់ពីប្អូនប្រុសអាយុ១២ឆ្នាំដែលស្លាប់ដោយអត់ឃ្លាន ។ ប្អូនរបស់សុផល សុំឲ្យ សុផល កាត់ដៃស្តាំរបស់គាត់ចោលដើម្បីទុកជាការចងចាំ ។*

*ជាង៣០ឆ្នាំក្រោយមក តោ សុផល ចង់ឲ្យ អៀង សារី ស្លាប់ ។ «ហេតុអ្វីបានជា អៀង សារី ទទួលបានការព្យាបាលតាមផ្នែកវិជ្ជសាស្ត្រ រីឯគាត់និងគ្រួសាររបស់គាត់មិនទទួលបានការព្យាបាលអ្វីសោះនៅអំឡុងរបបខ្មែរក្រហម» ។*

*តោ សុផល មានភាពខឹងសម្បាខ្លាំងណាស់ ។*

*សុផល មិនជឿថាតុលាការអាចលុបបំបាត់ការឈឺចាប់របស់គាត់បានទេ ។ ប្រជាជនដែលរស់នៅទីក្រុងមានលុយ ដូច្នេះគេអាចបំភ្លេចការតស៊ូនៅអតីតកាលរបស់គេបាន ប៉ុន្តែអ្នកដែលរស់នៅជនបទនឹងមិនបំភ្លេចពីរឿងនេះទេ ។ ខ្ញុំនឹងមិនសប្បាយប្រសិនបើ អៀង សារី ត្រូវបានដោះលែង ។ អៀង សារី ប្រហែលជាមិនបានប្រព្រឹត្តិឧក្រិដ្ឋកម្មដោយខ្លួនឯងទេ ប៉ុន្តែគាត់ត្រូវទទួលខុសត្រូវពីព្រោះគាត់គឺជាអ្នកបញ្ជាពីក្រោយ ។*

*ហ៊ុយ យុទ្ធ មកពីខេត្តកំពត គាត់បានបាត់បង់សាច់ញាតិ១០នាក់នៅរបបខ្មែរក្រហម ហើយគាត់ចង់ឲ្យតុលាការដំណើរនិងបញ្ចប់កាត់ក្តីឲ្យបានលឿន ។ «ប្រសិនបើមានការពន្យារពេលយូរពេក មេដឹកនាំខ្មែរក្រហមប្រហែលជានឹងស្លាប់ ។ ខ្ញុំពិតជាមានអារម្មណ៍សប្បាយចំពោះការកាត់ទោសនេះណាស់ ពីព្រោះការកាត់សេចក្តីនេះ គឺសម្រាប់អនាគតរបស់ក្មេងជំនាន់ក្រោយ» ។*

*ដោយយោងទៅតាមការបដិសេធមិនដោះលែង អៀង សារី តោ សុផល ដែលចង់ឲ្យអៀង សារី ស្លាប់ មានអារម្មណ៍ថាព្រលឹងនៃសមាជិកគ្រួសាររបស់គាត់ទទួលបានការសងសឹកហើយ ។*

*ហ៊ុយ យុទ្ធ ជឿថា «ទោះបីជាកំហឹងរបស់គាត់នឹងមិនសាបរលាប ប៉ុន្តែយុត្តិធម៌តាមផ្លូវច្បាប់អាចបន្ធូរបន្ថយកំហឹងនោះបាន» ។* **ម៉ម កល្យានី**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ឡើងវិញនៅលើគេហទំព័ររបស់ខ្លួននៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ខាងមុខនេះ ។*

*អ្នកទាំងអស់គ្នាអាចស្តាប់ ថតចម្លង និងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រវិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។*

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# សេចក្តីថ្លែងការណ៍ពីរដ្ឋមន្ត្រីក្រសួងការបរទេស អៀង សារី

ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺកំពុងតែពុះពាររាល់ឧបសគ្គទាំងឡាយ ដើម្បីការពារសុវត្ថិភាពរបស់ខ្លួន ដោយពឹងពាក់ទៅលើឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី និងសិទ្ធិដ៏ពេញលេញក្នុងការសម្រេចលើជោគវាសនារបស់ពួកគេផ្ទាល់ ។ ការតស៊ូរបស់កម្ពុជាប្រជាធិបតេយ្យនាពេលបច្ចុប្បន្ន ដែលទាក់ទងជុំវិញសកម្មភាពឈ្លានពាន និងលេបទឹកដីដែលប្រព្រឹត្តឡើងដោយ «សាធារណរដ្ឋសង្គមនិយមវៀតណាម» គឺមិនមានសារសំខាន់ជាជាងការតស៊ូ ដើម្បីជាតិប្រឆាំងទៅនឹងសង្គ្រាមឈ្លានពានដែលប្រព្រឹត្តឡើងដោយពួកចក្រពត្តិអាមេរិកនោះទេ ដែលនៅអំឡុងពេលនោះ ប្រជាជនយើងនាំគ្នាធ្វើពលិកម្មដ៏ធំធេង ដើម្បីទទួលបាននូវឯករាជ្យភាព និងជ័យជម្នះ ដោយយកគោលការណ៍មិនចូលបក្សសម្ព័ន្ធជាមូលដ្ឋាន ។ ជាការពិតណាស់ ការតស៊ូរបស់កម្ពុជាប្រជាធិបតេយ្យនាពេលបច្ចុប្បន្ននេះគឺដើម្បីធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យរស់នៅបានគង់វង្ស រីកចម្រើន និងឈានទៅរកឯករាជ្យភាព សន្តិភាព និងក្លាយជាប្រទេសមិនចូលបក្សសម្ព័ន្ធ ។ កាលពីអតីតកាលសហគមន៍ដ៏ធំបំផុតនៃប្រទេសដែលមិនចូលបក្សសម្ព័ន្ធគឺបានគាំទ្រយ៉ាងសកម្មទៅលើហេតុផលដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជា ។ ប៉ុន្តែពួកគេក៏បន្តការយកចិត្តទុកដាក់របស់ខ្លួនយ៉ាងខ្លាំងក្លាលើសកម្មភាពឈ្លានពានរបស់វៀតណាមប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យផងដែរ ។ អាកប្បកិរិយាបែបនេះបានបន្ថែមនូវការលើកទឹកចិត្តចំពោះប្រជាជនកម្ពុជា ដែលតែងតែមានការប្តេជ្ញាចិត្តយ៉ាងមុតមាំលើគោលការណ៍មិនចូលបក្សសម្ព័ន្ធ និងពង្រឹងនូវជំនឿចិត្តក្នុងហេតុផលដ៏ត្រឹមត្រូវរបស់ពួកគេ ។

កម្ពុជាប្រជាធិបតេយ្យបានដឹងយ៉ាងច្បាស់ថាចលនាមិនចូលបក្សចូលបក្សសម្ព័ន្ធគឺប្រឈមមុខនឹងបញ្ហាលំបាកជាច្រើន ដែលបណ្តាលមកពីការជ្រៀតជ្រែកនិងលូកដៃរបស់ពួកចក្រពត្តិនិយម វាតទីនិយមនិងអ្នកគាំទ្ររបស់គេ ។ ដោយសារតែមូលហេតុមួយនេះហើយដែលធ្វើឲ្យការពិតត្រូវបានលាតត្រដាងទាំងអស់នៅក្នុងជម្លោះថ្មីៗនេះរវាងកម្ពុជា-វៀតណាម ។ ដោយគោរពទៅតាមគោលការណ៍មិនចូលបក្សសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យមានការរំពឹងទុកយ៉ាងជ្រាលជ្រៅថាសហគមន៍មិនចូលបក្សសម្ព័ន្ធអាចផ្តល់នូវពេលវេលា និងកេណ្ឌកម្លាំងទ័ពដើម្បីចូលរួមតស៊ូប្រឆាំងទៅនឹងសត្រូវនៅចំពោះមុខ ។

បុសគល់ដែលបណ្តាលឲ្យមានជម្លោះនាពេលបច្ចុប្បន្ននេះគឺបានរៀបរាប់នៅក្នុងសេចក្តីរាយការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ។ កាលពីប៉ុន្មានទសវត្សរ៍មុន ប្រទេសវៀតណាមបានកំណត់នូវគោលដៅយុទ្ធសាស្ត្រលើកទីបួនរបស់ខ្លួនដើម្បីបង្កើតនូវ «សហព័ន្ធឥណ្ឌូចិន» ដែលទាក់ទងនឹងប្រទេសមួយ គណបក្សមួយ និងប្រជាជនមួយ ។ ប្រទេសវៀតណាមចង់បង្ខំកម្ពុជាឲ្យចូលរួមក្នុង «សហព័ន្ធ» នេះ តាំងពីពេលនោះមក ។ ជាពិសេសតាំងពីឆ្នាំ១៩៧៥ មនការគាបសង្កត់គ្រប់បែបយ៉ាងទាំងអស់ ការលាតត្រដាង និងរក្សាអាថ៌កំបាំង សន្តិភាព និងសង្គ្រាមដែលត្រូវបានយកមកប្រើប្រាស់


អៀង សារី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ


អៀង សារី ក្នុងឆ្នាំ២០០៨

ដើម្បីសម្រេចបាននូវលទ្ធផលចុងក្រោយនេះ ។ ប៉ុន្តែវៀតណាម បានទទួលបរាជ័យបន្តៗគ្នានៅក្នុង ៖

- ផែនការណ៍អប់រំអំពី «សាមគ្គីភាពវិសាមញ្ញ» និង «មិត្តភាពពិសេស» ជាមួយកម្ពុជា
- ការស៊ើបអង្កេត និង ការធ្វើវិទ្ធង្សនា
- ការប៉ុនប៉ងចង់ធ្វើរដ្ឋប្រហារមកលើកម្ពុជា
- ការទន្ទ្រានរបស់កងទ័ពវៀតណាមមកលើព្រំដែនកម្ពុជា

ផែនការរបស់វៀតណាមខាងលើទាំងអស់នេះសុទ្ធតែទទួលបានការបរាជ័យទាំងអស់ ។ ដោយសារតែការបរាជ័យផ្ទួនៗនេះហើយទើបធ្វើឲ្យវៀតណាមចាប់ផ្តើមអនុវត្តនូវការវាយប្រហារមួយយ៉ាងខ្លាំងក្លាកាលពីបួនខែមុន ក្នុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ ។ សកម្មភាពនេះគឺដូចគ្នាទៅនឹងការធ្វើសង្គ្រាមដោយមិនប្រកាសជាមុនដើម្បីប្រឆាំងជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ កងទ័ពបដិវត្តន៍កម្ពុជាបានបោសសម្អាតកងទ័ពវៀតណាមឈ្លានពាន ។ យ៉ាងណាមិញទោះបីជាមានការបរាជ័យទាំងនេះក៏ដោយ ក៏កងទ័ពវៀតណាមនៅតែមិនបោះបង់ចោលគោលការណ៍របស់ខ្លួនក្នុងការបង្ខំឲ្យកម្ពុជាចូលរួម «សហព័ន្ធឥណ្ឌូចិន» ដែលគ្រប់គ្រងដោយវៀតណាមទាល់តែសោះ ។ ដោយសារតែមូលហេតុនេះហើយទើបធ្វើឲ្យស្ថានភាពនៅតែមានភាពតានតឹងដដែល ។ វៀតណាមនៅបន្តអនុវត្តសកម្មភាពយោធានិងធ្វើវិទ្ធង្សនាប្រឆាំងនឹងកម្ពុជាដដែល ។ កងទ័ពវៀតណាមនៅតែបន្តការផ្ទុះអាវុធ ដោយប្រើកាំភ្លើងខ្លីនិងកាំភ្លើងធំនៅតាមបណ្តោយព្រំដែនកម្ពុជា ។ វៀតណាមនៅតែបន្តការបញ្ជូនភ្នាក់ងារស៊ើបការណ៍ដើម្បីសង្កេតស្ថានភាពនៅកម្ពុជា ។ អំឡុងពេលដែលផែនការនេះត្រូវបានអនុវត្ត វៀតណាមបានរៀបចំកងទ័ពរបស់ខ្លួនរួចជាស្រេចមកហើយនៅតាមតំបន់ព្រំដែនដើម្បីឲ្យកម្ពុជាប្រជាធិបតេយ្យដឹងថាវៀតណាមធ្វើបែបនេះដើម្បីតែមូលហេតុមួយគត់នោះគឺបន្តពង្រីកការឈ្លានពានរបស់ខ្លួនមកលើកម្ពុជាក្នុង ឆ្នាំ១៩៧៨ ។ ជាងនេះទៅទៀត នៅលើឆាកអន្តរជាតិវៀតណាមបានមួលបង្កាច់រដ្ឋាភិបាលកម្ពុជាដែលត្រូវបានជ្រើសរើសដោយប្រជារាស្ត្រ ។ កម្ពុជាប្រជាធិបតេយ្យបានរំពឹងទុកយ៉ាងខ្លាំងចំពោះភាពចាស់ទុំផ្នែកនយោបាយរបស់មេដឹកនាំវៀតណាម ប៉ុន្តែអ្វីដែលវៀតណាមសម្តែងចេញចំពោះកម្ពុជាប្រជាធិបតេយ្យនោះគឺការព្យាយាមស្វែងរកភាពស្របច្បាប់ជា



អៀង សារី និងគណៈប្រតិភូបរទេសទស្សនាប្រាសាទនៅខេត្តសៀមរាប ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

លក្ខណៈអន្តរជាតិសម្រាប់សកម្មភាពជ្រៀតជ្រែកទាំងអស់និងគម្រោងការលេបយកទឹកដីរបស់ខ្លួន ។ តើវៀតណាមគួរតែមានសិទ្ធិដើម្បីអនុវត្តសកម្មភាពទាំងនេះឬទេ? បន្ទាប់ពីការបរាជ័យយ៉ាងធ្ងន់ធ្ងរ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ នៅមុនមួយថ្ងៃដែលវៀតណាមទាមទារឲ្យមានការចរចាគ្នា គឺនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ វៀតណាមបែរជាធ្វើការវាយប្រហារដោយកាំភ្លើងធំនៅកោះធំ ដែលមានទីតាំងនៅក្រោមទន្លេបាសាក់ខាងត្បូងទីក្រុងភ្នំពេញទៅវិញ ។ ការវាយប្រហារនេះដឹកនាំដោយកងវរសេនាធំថ្មើរជើងវៀតណាមបួនក្រុមដែលមានរថក្រោះខ្ទម្ពាគចក្រ និងយន្តហោះចម្បាំងជាជំនួយផង ។ នៅថ្ងៃទី៥, ៦, ៧ និង ៨ ខែកុម្ភៈ វៀតណាមបានបន្តការវាយប្រហាររបស់ខ្លួននៅតំបន់នេះ និងតំបន់ជាច្រើនទៀតនៅខេត្តស្វាយរៀង ។ ដូច្នេះថា តើវៀតណាមធ្វើការចរចាជាមួយកម្ពុជាដើម្បីអ្វីទៅ បើវៀតណាមនៅតែបន្តវាយប្រហារមកលើកម្ពុជាដដែល នៅអំឡុងពេលដែលវៀតណាមខ្លួនឯងកំពុងតែស្នើសុំឲ្យមានការចរចាគ្នា ។

កម្ពុជាប្រជាធិបតេយ្យមិនដែលធ្វើការបដិសេធលើគោលការណ៍ចរចារបស់វៀតណាមឡើយ ដូចដែលបានបញ្ជាក់យ៉ាងច្បាស់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ និងនៅក្នុងឯកសារផ្លូវការផ្សេងៗទៀតតាំងពីឆ្នាំ១៩៧៥មក ។

នៅខែមិថុនា ឆ្នាំ១៩៧៥ ថ្មីបើវៀតណាមកាន់កាប់កោះវៃ (កោះកម្ពុជា) ហើយកម្ពុជាប្រជាធិបតេយ្យខ្លួនឯងផ្ទាល់កំពុងតែជួបបញ្ហាផ្ទៃក្នុងជាច្រើនក៏ដោយ ក៏កម្ពុជាប្រជាធិបតេយ្យនៅតែដឹកនាំគណៈប្រតិភូទៅទីក្រុងហាណូយដើម្បីធ្វើការចរចាលើជម្លោះព្រំដែន ដែលពេលនោះមានវត្តមានរបស់លេខាធិការបក្ស អនុលេខាធិការនៃគណកម្មាធិការមជ្ឈិមបក្សកុម្មុនីស្តកម្ពុជានិងឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។ នៅខែឧសភា ឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានអញ្ជើញគណៈប្រតិភូវៀតណាមមកធ្វើទស្សនកិច្ចនៅកម្ពុជាដើម្បីបន្តការចរចា ។ ទន្ទឹមនឹងពេលនោះផងដែរ កម្ពុជាប្រជាធិបតេយ្យមានបំណងចង់ទទួលបាននូវដំណោះស្រាយដោយសន្តិភាពដែលនឹងអាចបន្តរក្សាទំនាក់ទំនងជាធម្មតាជាមួយនឹងវៀតណាមតាមរយៈគណៈកម្មាធិការលីអាយស៊ិន ដែលស្ថិតនៅកម្រិតមជ្ឈិម តំបន់ និងស្រុក ។ ប៉ុន្តែវៀតណាមនៅតែមិនអើពើនឹងបំណងល្អរបស់កម្ពុជាឡើយ បែរជាសម្តែងចេញនូវអាកប្បកិរិយាផ្ទុយពីសេចក្តីថ្លែងការណ៍របស់ខ្លួនដែលបានធ្វើនៅឆ្នាំ១៩៦៦ និងឆ្នាំ១៩៦៧ ដែលនិយាយពីការទទួលស្គាល់ព្រំដែនកម្ពុជានាពេលបច្ចុប្បន្ន ហើយថែមទាំងបានសន្យាថានឹងគោរពទៅតាមការកំណត់ទាំងនោះទៀតផង ។ ម្យ៉ាងវិញទៀត វៀតណាមធ្លាប់មានទំនាក់ទំនងតាមរយៈគណៈកម្មាធិការលីអាយស៊ិន ដើម្បីធ្វើវិទ្ធង្សនាញុះញង់ក្នុងបំណងចង់បង្កចលាចល និងធ្វើរដ្ឋប្រហារនៅខែកញ្ញា១៩៧៥ ខែមេសា ១៩៧៦ ខែកញ្ញា ១៩៧៦ ខែមេសា ១៩៧៧ និងខែកញ្ញា ១៩៧៧ ។

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៧ ស្ថិតក្នុងស្ថានភាពដ៏តានតឹងនេះ កម្ពុជាបានស្នើសុំភាគីទាំងពីរនូវចំណុចដូចខាងក្រោមៈ

១) ជៀសវាងទំនាស់ដោយប្រើអាវុធនៅតាមបណ្តោយព្រំដែនទាំងជើងគោកនិងជើងទឹក ។

២) តាំងចិត្តថានឹងមិនជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេត ការឈ្លានពានលេបយកទឹកដី ការធ្វើវិទ្ធង្សនា និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក ។

៣) ហាមមិនឲ្យមានការដាក់ទ័ពនៅចម្ងាយតិចជាង៥០០ ទៅ១,០០០ម៉ែត្រពីព្រំដែនបច្ចុប្បន្ននោះទេ ក្នុងគោលបំណងបញ្ចៀសនូវទំនាស់ដោយប្រើអាវុធ ។

៤) ត្រូវអប់រំទាហាននិងប្រជាជនរបស់ភាគីនីមួយៗឲ្យដឹងច្បាស់ពីគោលការណ៍មិត្តភាព និងសាមគ្គីភាព ការគោរពគ្នាទៅវិញទៅមក ភាពស្មើគ្នា និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក ។

ការស្នើសុំរបស់កម្ពុជាទាំងអស់នេះគឺត្រូវបានធ្វើឡើងដើម្បីបង្កើតនូវបរិយាកាសស្រុះស្រួលគ្នា និងជឿជាក់គ្នាទៅវិញទៅមកដើម្បីអំណោយផលដល់ការជួបមុខគ្នានៅថ្ងៃក្រោយទៀត ។ ឥឡូវនេះវៀតណាមមិនទទួលខុសត្រូវម្តងទៀតហើយ ។ ផ្ទុយគ្នាទៅនឹងដើមខែកក្កដា ឆ្នាំ១៩៧៧ វៀតណាមបានពង្រីកនូវសកម្មភាពឈ្លានពានរបស់ខ្លួនមកលើកម្ពុជា ។ ចំពោះកម្ពុជាវិញ គឺមិនបានប្រកាសជាសាធារណៈពីសកម្មភាពឈ្លានពានទាំងអស់នេះទេ ពីព្រោះកម្ពុជាចង់ដោះស្រាយបញ្ហាទាំងនេះដោយសន្តិភាពនិង

ស្មោះស្ម័គ្របំផុត ។ ប៉ុន្តែចំពោះភាគីវៀតណាមវិញ គឺបានអនុវត្តនូវសកម្មភាពការទូតដែលធ្វើឡើងដើម្បីមួលបង្កាច់ និងដាក់គម្លាតកម្ពុជាឲ្យឆ្ងាយពីឆាកអន្តរជាតិ ។

ប្រសិនបើទំនាស់ព្រំដែននាពេលបច្ចុប្បន្ននេះគឺគ្រាន់តែជាទំនាស់ព្រំដែនធម្មតាមួយ ចុះហេតុអ្វីបានជានៅចុងឆ្នាំ១៩៧៧ កងទ័ពវៀតណាមឈ្លានពានចូលទឹកដីកម្ពុជាជាង៣០ម៉ែត្រ? ហេតុអ្វីបានជាកងទ័ពវៀតណាមកម្ទេចរចនាសម្ពន្ធ័របស់រដ្ឋាភិបាលកម្ពុជាដើម្បីបញ្ចូលដៃជើងរបស់ខ្លួនក្នុងជួររដ្ឋបាល? ហេតុអ្វីបានជាវៀតណាមជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពជាច្រើនក្នុងការផ្តួលរលំរដ្ឋាភិបាលបច្ចុប្បន្នរបស់កម្ពុជាប្រជាធិបតេយ្យ? ចម្លើយឆ្លើយតបទៅនឹងសំណួរទាំងបីនេះ គឺវៀតណាមចង់បាន «សហព័ន្ធឥណ្ឌូចិន» របស់ខ្លួនតែប៉ុណ្ណោះ ។ សកម្មភាពរបស់វៀតណាមទាំងប៉ុន្មានមិនមានអ្វីថ្មីនោះទេ ។ ពួកចក្រពត្តិ ពួកអាណានិគម ពួកសក្តិភូមិវៀតណាម និងបនប្រតិកិរិយា បានលេបយកនូវទឹកដីរាប់ម៉ឺនគីឡូម៉ែត្រការ៉េបញ្ចូលជាទឹកដីរបស់ខ្លួន ដូចឧទាហរណ៍ជាក់ស្តែងទឹកដីកម្ពុជាក្រោម ។ ប្រជាជនខ្មែរទាំងអស់សុទ្ធតែដឹងពីរឿងរ៉ាវនេះ ប៉ុន្តែគ្រាន់តែប្រជាជនទាំងនោះគិតថា រឿងដែលកន្លងផុតឲ្យវាកន្លងផុតទៅចុះ កុំរំពឹកវាទៀត ។ អ្វីដែលប្រជាជនចង់បាននោះគឺការរស់នៅក្នុងសុខសន្តិភាព ភាពស្មោះត្រង់ និងភាពថ្លៃថ្នូរដោយសុខចិត្តរស់នៅក្រោមអំណាចនៃទឹកដីដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងឯកសារប្រវត្តិសាស្ត្រ អត្ថបទផ្សេងៗនិងផែនទី ។ នៅអំឡុងពេលនៃការចរចារវាងកម្ពុជា និងកងទ័ពរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងនៅក្នុងខែសីហា និងកញ្ញា ឆ្នាំ១៩៦៦ និងនៅក្នុងសេចក្តីរាយការណ៍ផ្សេងៗដែលចេញផ្សាយដោយរណសិរ្សរំដោះជាតិនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៦៧ និងការចុះផ្សាយរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៦៧ វៀតណាមបានប្រកាសថា ខ្លួនទទួលស្គាល់ព្រំប្រទល់ទឹកដីកម្ពុជា ហើយនឹងបន្តការគោរពតាមការកំណត់នេះដូចមានចែងក្នុងកិច្ចព្រមព្រៀង ។ តែឥឡូវនេះវាកើតឡើងទៀតហើយ ហេតុអ្វីបានជាវៀតណាមនាពេលបច្ចុប្បន្ននេះបដិសេធមិនអនុវត្តតាមការសន្យារបស់ខ្លួនទៅវិញ?

នៅក្នុងសេចក្តីរាយការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជា-ធិបតេយ្យចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ គឺបានអះអាងយ៉ាងច្បាស់លាស់ថា ទំនាស់នាពេលបច្ចុប្បន្ននេះអាចបញ្ចប់បានតាមមធ្យោបាយតែមួយគត់ ប្រសិនបើវៀតណាមយល់ព្រមបញ្ចប់នូវសកម្មភាពឈ្លានពាន និងលេបយកទឹកដីកម្ពុជា និងការធ្វើវិទ្ធង្សនា ។ ម្យ៉ាងវិញទៀត ប្រសិនបើវៀតណាមព្រមគោរពតាមឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ ជាពិសេសគោរពសិទ្ធរបស់ប្រជាជនកម្ពុជាក្នុងការសម្រេចនូវជោគវាសនារបស់ពួកគេ ។ ទាំងអស់នេះ ប្រសិនបើវៀតណាមអាចធ្វើបាននោះមិត្តភាពរវាងកម្ពុជាវៀតណាមពិតជាអាចស្តាបនា ពង្រឹង និងរីកចម្រើនឡើងវិញជាក់ជាមិនខាន ។ ទាំងនេះគឺជាបំណងប្រាថ្នារបស់កម្ពុជាប្រជាធិបតេយ្យដែលជាប្រទេសតូចមួយមានចំនួនប្រជាជនតិចតួចនិងពុំមានកងទ័ពឈរជើងនៅក្រៅប្រទេសនោះទេ ។ កម្ពុជាត្រូវការពេលវេលា និងសន្តិភាពសម្រាប់កសាងជាតិមាតុភូមិ ជាពិសេសដើម្បីធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើង ។ កម្ពុជាគ្មានហេតុផលណាក្នុងការបង្កសង្គ្រាមនោះទេ កម្ពុជាត្រូវការសន្តិភាព តែមិនមែនសង្គ្រាមនោះទេ ។

យ៉ាងណាមិញ ទោះជាអំឡុងពេលដែលវៀតណាមបដិសេធមិនធ្វើតាមគោលការណ៍ស្រុះស្រួលនេះក៏ដោយ ក៏ចាត់ទុកថាគ្មានកំហុសឆ្គងដែរ ប៉ុន្តែកម្ពុជានៅតែបន្តការប្រុងប្រយ័ត្នជានិច្ច ។ ក្នុងការការពារផលប្រយោជន៍ដែលមិនអាចផ្លាស់ប្តូរបាន និងមានសារសំខាន់ជាទីបំផុតរបស់ខ្លួន កម្ពុជាប្រជាធិបតេយ្យគឺបានស្វែងយល់យ៉ាងច្បាស់ពីកាតព្វកិច្ច និងតួនាទីរបស់ខ្លួនទៅលើចលនាមិនចូលបក្សសម្ព័ន្ធ ។ នេះត្រូវបានអះអាងថា ការតស៊ូរបស់កម្ពុជាប្រជាធិបតេយ្យនាពេលបច្ចុប្បន្នជាការចូលជាបច្ច័យយ៉ាងសមហេតុផលមួយដើម្បីពង្រឹងនូវឯករាជ្យភាព អធិបតេយ្យភាព និងសន្តិភាពសម្រាប់អាស៊ីអាគ្នេយ៍ និងពិភពលោកទាំងមូលក្នុងការប្រឆាំងទៅនឹងមហិច្ឆតារបស់ពួកចក្រពត្តិនិយម វាតទីនិយម និងបនបរិវាររបស់ពួកគេ ។ ការតស៊ូនេះក៏ដើរតួយ៉ាងសំខាន់ក្នុងការលើកស្ទួយគោលការណ៍មិនចូលបក្សសម្ពន្ធ័ដែរ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា D៣០៤៦៩**

# របាយការណ៍វេទិកាពិភាក្សាតាមភូមិនៅស្រុកបាធាយ ខេត្តកំពង់ចាម

អ្នកស្រី ហួត សាវ៉ន កំពុងអង្គុយនៅក្នុងសាលាឆាន់ ហើយ


អ្នកស្រី ហួត សាវ៉ន

សូត្រធម៌តាមព្រះសង្ឃនៅក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌដែលជាបុណ្យប្រពៃណីសម្រាប់ឧទ្ទិសដល់ព្រលឹងអ្នកដែលបានស្លាប់ទៅ ។ នៅថ្ងៃទី២២ ខែកញ្ញា នៅក្នុងវត្តសេរីសាគរ ស្ថិតនៅក្នុងឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម អ្នកស្រី ហួត ដែលជាអតីតសមាជិកក្រុមប្រឹក្សាឃុំនិងជាអ្នកចូលរួមក្នុងសវនាការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញមកទទួលក្រុមបុគ្គលិកឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកស្រី ហួត ជាមនុស្សសំខាន់មួយរូបដែលក្រុមការងារត្រូវទាក់ទងដើម្បីរៀបចំកិច្ចពិភាក្សាអំពីដំណើរការនីតិវិធីរបស់តុលាការខ្មែរក្រហម ជាពិសេសសវនាការ អៀង ធីរិទ្ធ កាលពីខែឧសភា ឆ្នាំ២០០៨ ដោយបានស្វាគមន៍យើងទាំងអស់គ្នាជាមួយនឹងទឹកមុខញញឹមនិងបង្ហាញពីភាពពេញចិត្តចំពោះការវិលត្រឡប់មកភូមិនេះម្តងទៀតរបស់យើង ។ គាត់ជាអ្នកចូលរួមនៅក្នុងគម្រោងឯកសាររស់ដែលបានប្រមូលអ្នកភូមិឲ្យមកចូលរួមនៅក្នុងសវនាការកាលពីខែឧសភា ។ តាមរយៈអ្នកស្រី ហួត ក្រុមគម្រោងមានបំណងហៅអ្នកចូលរួមក្នុងសវនាការ៩នាក់ផ្សេងទៀតដើម្បីធ្វើការអង្កេតទៅលើសវនាការជាមួយសមាជិករបស់សហគមន៍អ្នកស្រី ហួត ។ អ្នកដែលបានមិនបានចូលរួមក្នុងសវនាការនឹងមានឱកាសស្តាប់ការរៀបរាប់ពីអ្នកតំណាងសហគមន៍ដែលបានចូលរួមនិងដើម្បីបង្ហាញពីចម្ងល់និងផ្តល់យោបល់ចំពោះតុលាការខ្មែរក្រហម ។

បន្ទាប់ពីបាននិយាយជាមួយព្រះសង្ឃ និងគណៈកម្មការវត្ត ក្រុមការងារអាចយកសាលាឆាន់ ដើម្បីបញ្ចាំងខ្សែភាពយន្តនិងពិភាក្សា ។ អ្នកភូមិប្រហែល៥០នាក់មកពីភូមិពីរគឺភូមិស្រីង្គនិងស្វាយព្រៃ ដែលមកធ្វើបុណ្យនៅវត្តសេរីសាគរ នៅថ្ងៃភ្ជុំបិណ្ឌត្រូវបានអញ្ជើញឲ្យចូលរួមក្នុងវេទិកាពិភាក្សា ។ នេះជាឱកាសដ៏កម្រសម្រាប់អ្នកភូមិអាចជួបគ្នានិងពិភាក្សាអំពីតុលាការខ្មែរក្រហម ។ ទោះបីជាមានអ្នកចូលរួមក្នុងសវនាការអង្គបុរេជំនុំជម្រះតែប៉ុន្មាននាក់ក្នុងការប្រជុំក៏ដោយ ប៉ុន្តែមានអ្នកភូមិជាច្រើននាក់រួមទាំងយុវជនផងបានចូលរួមទស្សនាការបញ្ចាំងភាពយន្តនេះ ។ ពេលចាប់ផ្តើមពិភាក្សាក្រុមការងារបានចែកទស្សនាវដ្តីស្វែងរកការពិតចំនួន៥០ក្បាលឲ្យអ្នកភូមិ បើទោះជាចំនួននេះមិនគ្រប់គ្រាន់សម្រាប់អ្នកចូលរួមក៏ដោយ ។

## សកម្មភាពនៃវេទិកាពិភាក្សា

អ្នកចូលរួមទាំងអស់បានជួបជុំគ្នានៅក្នុងសាលាឆាន់ ដោយមានឮសំឡេងធម្មទេសនារបស់ព្រះសង្ឃនិងអ្នកចូលរួមភាគច្រើនជាស្ត្រីវ័យចំណាស់ដែលមកធ្វើបុណ្យសាសនា ។ បន្ទាប់ពីសុំឲ្យអ្នកចូលរួមទាំងអស់គ្នាអង្គុយចុះ លោក វ៉ាន់ថាន់ ពៅដារ៉ា ដែលជានាយករងមជ្ឈមណ្ឌលឯកសារកម្ពុជានិងអ្នកជួយសម្រួលដល់ក្រុមការងារបានឡើងនិយាយណែនាំដល់អ្នកចូលរួម ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បាននិយាយរៀបរាប់សង្ខេបអំពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងឯកសាររស់ និងគោលបំណងនៃវេទិកាពិភាក្សានេះ ។ បន្ទាប់មក លោកនិយាយអំពីដំណើរការរបស់តុលាការ និងរៀបរាប់ពីខ្សែភាពយន្តដែលនឹងត្រូវបញ្ចាំង ។

ទស្សនិកជនបានស្តាប់សេចក្តីសង្ខេបអំពីភាពយន្តឯកសារដែលមានចំណងជើងថា «ក្រោយជញ្ជាំងមន្ទីរស-២១» ដែលភាពយន្តនេះបង្ហាញពីអតីតអ្នកយាមគុកស-២១ និងអតីតអ្នកទោសពីរនាក់ ។ ក្រុមការងារសង្កេតឃើញថាទស្សនិកជនភាគច្រើនរួមទាំងអ្នកមានវ័យចំណាស់ ក្មេងៗ និងយុវជនចូលចិត្តមើលខ្សែភាពយន្តនោះ ។ ទស្សនិកជនចូលចិត្តមើលឈុតដែលមានប្រជាជនលើកភ្លឺ ជីកប្រឡាយ និងលើកដី ពីព្រោះវារំឭកអំពីបទពិសោធន៍ដែលគាត់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។

បន្ទាប់ពីបញ្ចាំងភាពយន្តឯកសារ ក្រុមការងារក៏បានបញ្ចាំង

ពីសវនាការអង្គបុរេជំនុំជម្រះ អៀង ធីរិទ្ធ ដើម្បីឆ្លុះបញ្ចាំងអំពីដំណើរការនីតិវិធីរបស់សវនាការ និងជំរុញឲ្យមានការពិភាក្សា ។ ក្រុមការងារបានចាក់បញ្ចាំងពីសវនាការតាំងពីដើមរហូតដល់ចប់ ពោលគឺពេលដែលចៅក្រមប្រកាសសាលក្រម ។ នៅពេលដែលចៅក្រមសួរសំណួរជនត្រូវចោទ ស្ត្រីវ័យចំណាស់មួយចំនួនដែលអង្គុយនៅជួរមុខបានខិតមកមុខដើម្បីមើលឲ្យកាន់តែច្បាស់ ។ អ្នកទាំងនោះបានចង្អុលមុខជនត្រូវចោទ ហើយខ្សឹបដាក់គ្នាអំពីរូបរាងរបស់ជនត្រូវចោទ ពីព្រោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមកម្របង្ហាញមុខណាស់ ដែលនេះជាលើកដំបូងហើយដែលអ្នកភូមិបានឃើញមុខនិងស្តាប់ឮសំឡេងរបស់ អៀង ធីរិទ្ធ ។

នៅពេលដែលបញ្ចាំងភាពយន្តរួច លោក វ៉ាន់ថាន់ ពៅដារ៉ា សង្ខេបពីដំណើរការរបស់សវនាការ ហើយពន្យល់សង្ខេបអំពីតួនាទីរបស់ចៅក្រម សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត សហមេធាវី និងវត្តមានអ្នកសំខាន់មួយចំនួននៅក្នុងសវនាការ ។ លោកបានលើកឡើងពីសម្តីរបស់ក្រុមនីមួយៗដែលចូលរួមក្នុងសវនាការនិងពន្យល់ពីតួនាទីចម្បងរបស់ក្រុមនោះ ។ លោកសង្កត់ធ្ងន់ថា នៅក្នុងតុលាការជនត្រូវចោទមានសិទ្ធិជ្រើសរើសមេធាវី ហើយអាចតំណាងដោយមេធាវី ។ នៅចុងក្រោយលោក ដារ៉ា បានពន្យល់ពីសេចក្តីសម្រេចរបស់ចៅក្រមទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ ។ បន្ទាប់មកក្រុមការងារបានផ្តល់ឱកាសឲ្យប្រជាជនសួរសំណួរនិងបញ្ចេញទស្សនៈ ។

អ្នកចូលរួមជាច្រើនមិនសូវយល់ពីសវនាការ ជាក់ស្តែងមានអ្នកចូលរួមម្នាក់សួរថាហេតុអីបានជាត្រូវមានក្រុមពីរដែលក្រុមមួយចង់ឲ្យជនត្រូវចោទស្ថិតនៅក្នុងការឃុំឃាំង ហើយក្រុមមួយទៀតចង់ឲ្យដោះលែងជនត្រូវចោទ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា ពន្យល់ពីអំណះអំណាងរបស់សហព្រះរាជអាជ្ញានិងមេធាវីការពារក្តី ។ សហព្រះរាជអាជ្ញាលើកពីហេតុផលដើម្បីបន្តឃុំខ្លួនជនត្រូវចោទ រីឯមេធាវីការពារក្តីលើកអំណះអំណាងដែលត្រូវដោះលែង អៀង ធីរិទ្ធ ។ ព្រះរាជអាជ្ញាអះអាងថា គួរតែឃុំខ្លួន អៀង ធីរិទ្ធ ដើម្បីរក្សាសន្តិសុខរបស់សាក្សីនិងធានាឲ្យមានសណ្តាប់ធ្នាប់សាធារណៈ ។ មេធាវីការពារក្តីផ្តល់ហេតុផលឲ្យដោះលែង អៀង ធីរិទ្ធ ដោយសម្អាងថា គាត់ត្រូវទទួលការព្យាបាលនៅក្រៅមណ្ឌលឃុំខ្លួន ។

អ្នកភូមិម្នាក់ទៀតនៅតែមានចម្ងល់អំពីបញ្ហាដែលចោទឡើងនៅក្នុងសវនាការ ។ គាត់ឆ្ងល់ថាហេតុអ្វីបានជានៅក្នុងសវនាការមិនមាននិយាយអំពីឧក្រិដ្ឋកម្មដែលជនត្រូវចោទបានប្រព្រឹត្ត ។ លោក វ៉ាន់ថាន់ ពៅដារ៉ា ពន្យល់ថា សវនាការអង្គបុរេជំនុំជម្រះមិននិយាយអំពីឧក្រិដ្ឋកម្មដែលជនត្រូវចោទបានប្រព្រឹត្តទេ គឺគ្រាន់តែផ្តោតទៅលើបញ្ហាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នមុនពេលមានសវនាការប៉ុណ្ណោះ ។ ប្រជាជនដែលចូលរួមក្នុងការពិភាក្សាបាននិយាយពីចំណុចដែលគេយល់និងមិនយល់ ។ អ្នកចូលរួមទាំងអស់មិនមានឱកាសសួរសំណួរទាំងអស់គ្នាទេ ដោយសារពេលវេលាកាន់តែខិតទៅមុខ ហើយអ្នកចូលរួមទាំងអស់ត្រូវការធ្វើបុណ្យនៅក្នុងវត្តបន្តទៀត ។ ទោះជាយ៉ាងនេះក្តី អ្នកចូលរួមទាំងអស់បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសំណួរដែលចោទឡើង និងចម្លើយរបស់ក្រុមការងារ ។ វេទិកាពិភាក្សាបានបញ្ចប់ក្នុងរយៈពេលពីរម៉ោងបន្ទាប់ពីបញ្ចាំងខ្សែភាពយន្តនិងការពិភាក្សាគ្នា ។

នៅថ្ងៃទី២៣ ខែកញ្ញា ដែលជាថ្ងៃទីពីរ ក្រុមការងារបានវិលត្រឡប់មកវត្តម្តងទៀតដើម្បីសម្ភាសអ្នកដែលបានចូលរួមក្នុងការពិភាក្សាអំពីបទពិសោធន៍ដែលគេបានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ព្រមទាំងស្រង់យោបល់និងទស្សនៈដែលគេមានចំពោះតុលាការខ្មែរក្រហមនិងកម្មវិធីវេទិកាពិភាក្សា ។ ដោយសារតែពិធីបុណ្យភ្ជុំបិណ្ឌនៅតែបន្ត បណ្តាលឲ្យមានតែអ្នកចូលរួមពីរនាក់អាចឆ្លៀតឱកាសនិយាយពីបទពិសោធន៍របស់គាត់ និង


លោក វ៉ាន់ថាន់ ពៅដារ៉ា ពន្យល់អ្នកភូមិអំពីដំណើរការតុលាការខ្មែរក្រហម

*ពីរនាក់ទៀតផ្តល់ទស្សនៈរបស់គេអំពីតុលាការ ។ គម្រោងក្នុងការស្រង់មតិអ្នកចូលរួមត្រូវបានរំសាយចោលពីព្រោះអ្នកភូមិជាប់រវល់ធ្វើបុណ្យ ។*

## រឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នកចូលរួមនិងទស្សនៈចំពោះតុលាការខ្មែរក្រហម

*យោងទៅតាមបទសម្ភាសបានឲ្យដឹងថាបទពិសោធន៍ដែលប្រជាជននៅក្នុងឃុំសណ្តែកបានជួបប្រទះនៅក្នុងរបបខ្មែរក្រហមមានលក្ខណៈស្រដៀងគ្នា លើកលែងតែកន្លែងដែលគេរស់នៅ ។ នូវ ខាន់ មកពីភូមិស្រឹង្គ មានអាយុ១០ឆ្នាំ នៅក្នុងរបបខ្មែរក្រហមបានរៀបរាប់ថា នៅពេលដែលគាត់លួចស្រូវពីវាលស្រែ ឈ្លបខ្មែរក្រហមប៉ុន្មាននាក់ក៏ចាប់គាត់ចងនឹងខ្សែព្យួរ ហើយវាយគាត់រហូតដល់សន្លប់ ។ គាត់មានការឈឺចាប់ណាស់នៅពេលដែលរំឭកពីការចងចាំនេះ ។ គាត់និយាយថា «ខ្សែភាពយន្តនេះធ្វើឲ្យគាត់នឹកទៅដល់ពេលដែលគាត់ត្រូវបានឃុំខ្លួននៅមន្ទីរឃុំ» ។ គាត់មានសំណាងល្អដោយសារថានៅពេលគាត់រត់ចេញពីមន្ទីរឃុំខ្មែរក្រហមចាប់បានក្មេងម្នាក់ទៀត ហើយយល់ថាជាគាត់ ។ គាត់និយាយប្រាប់ក្រុមការងារថាគាត់មិនភ្លេចនូវអ្វីដែលខ្មែរក្រហមធ្វើមកលើគាត់ទេ ។ ការឈឺចាប់ រួមទាំងកំហឹងធ្វើឲ្យគាត់ចង់សងសឹកនឹងខ្មែរក្រហមណាស់ ។ គាត់បានប្រាប់ក្រុមការងារថាគាត់ចង់ឲ្យតុលាការកាត់ទោសប្រហារជីវិតមេដឹកនាំខ្មែរក្រហម ។*

*ស្ត្រីវ័យចំណាស់ម្នាក់ទៀតឈ្មោះ សៀន ប៊ិន មានការខឹងសម្បាជាខ្លាំងចំពោះកម្មាភិបាលខ្មែរក្រហមដែលបានវាយប្តីរបស់គាត់រហូតដល់ស្លាប់ ។ គាត់អាណិតប្តីជាខ្លាំង ព្រោះប្តីគាត់គ្រាន់តែលួចស្រូវពីស្រែដើម្បីបំពេញការអត់ឃ្លានរបស់គាត់ប៉ុណ្ណោះ ប៉ុន្តែខ្មែរក្រហមចាប់គាត់ រួចធ្វើទារុណកម្មរហូតដល់ស្លាប់ ។ គាត់និយាយថា «គាត់បានរុំសាកសពប្តីគាត់ដោយកន្ទេលចាស់មួយប្រៀបបាននឹងសត្វដើម្បីយកទៅកប់» ។ ការឈឺចាប់នៅក្នុងចិត្តគាត់មិនអាចសាបរលាបបានឡើយដរាបណាយុត្តិធម៌នៅមិនទាន់បានរកឃើញ ។ គាត់បន្ថែមទៀតថា «ខ្ញុំចង់ឃើញមេដឹកនាំទាំងនោះត្រូវបានកាត់ទោស ធ្វើដូច្នេះទើបមានយុត្តិធម៌» ។ ស្ត្រីចំណាស់អាយុ៧៦ឆ្នាំម្នាក់រូបនេះមិនចាប់អារម្មណ៍ទៅលើដំណើរការនីតិវិធីទេ គាត់គ្រាន់តែព្រួយបារម្ភពីលទ្ធភាពនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសប៉ុណ្ណោះ ។*

*មាន ហេង មកពីភូមិពោធិ៍ស្ពាន និយាយរៀបរាប់ពីប្រវត្តិស្រដៀងៗគ្នាដែលគាត់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ភូមិរបស់គាត់ត្រូវបានកាន់កាប់ដោយទាហានខ្មែរក្រហមនិងលន់ នល់ ។ ខ្មែរក្រហមស្ទើរតែគ្រប់គ្រងភូមិទាំងមូលរួមទាំងផលិតផលកសិកម្មផង ។ អ្នកភូមិដែលរស់នៅជាមួយខ្មែរក្រហមត្រូវបានរៀបចំឲ្យរស់នៅរួមនិងហូបរួម មុនពេលថ្ងៃជ័យជម្នះ ឆ្នាំ១៩៧៥ ។ ហេង ដែលមានអាយុ៥៥ឆ្នាំ គួញត្អែរថាអ្វីដែលគាត់ជួបប្រទះមិនខុសពី ខាន់ និង ប៊ិន ប៉ុន្មានទេ ភាពស្រេកឃ្លាន ធ្វើឲ្យគាត់សម្រេចចិត្តលួច ទោះបីជាគាត់ដឹងថានោះជាកំហុសធ្ងន់ធ្ងរក៏ដោយ ។ គាត់មានសំណាងល្អដែលចៀសផុតពីការចោទប្រកាន់ទាំងអស់ ។*

*កម្រិតយល់ដឹងអំពីតុលាការរបស់អ្នកចូលរួមក្នុងសវនាការមានការកើនឡើង ។ ហួត សាវ៉ន ដែលដឹកនាំក្រុមសង្កេតការណ៍ក្នុងសវនាការអង្គបុរេជំនុំជម្រះបាននិយាយប្រាប់ក្រុមរបស់យើងថាបន្ទាប់ពីទស្សនាតុលាការគាត់ចាប់ផ្តើមចាប់អារម្មណ៍នឹងព័ត៌មានតុលាការ ។ បច្ចុប្បន្នគាត់មានយល់ដឹងអំពីតុលាការនិងដំណើរការនីតិវិធីរបស់តុលាការ ហើយគាត់អាចពន្យល់នូវអ្វីដែលគាត់យល់ទៅកាន់អ្នកជិតខាងរបស់គាត់ ។ សាវ៉ន ក៏ដូចជា ខាន់ និង ប៊ិន ដែរ គាត់ព្រួយបារម្ភពីវ័យចំណាស់របស់មេដឹកនាំខ្មែរក្រហម ។ គាត់ស្នើឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យបានឆាប់ ។ ចំពោះវេទិកាពិភាក្សា គាត់ចង់ឲ្យមានការពិភាក្សាបែបនេះនៅគ្រប់ឃុំក្នុងទូទាំងប្រទេស ពីព្រោះនេះជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយព័ត៌មាន និងជំរុញឲ្យអ្នកភូមិអាចនិយាយរៀបរាប់ពីបទពិសោធន៍ដែលគាត់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ហើយនឹងជួយការពារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យផង ។ នៅពេលដែលក្រុមការងារសួរទៅអ្នកសម្ភាសន៍ថាចង់ធ្វើការអង្កេតនៅសវនាការអង្គបុរេជំនុំជម្រះឬទេ អ្នកទាំងនោះសុទ្ធតែយល់ស្រប ពីព្រោះគាត់យល់ឃើញថានៅពេលដែលគាត់ឃើញការកាត់ក្តីពិតប្រាកដ វានឹងអាចធ្វើឲ្យការឈឺចាប់ដែលគេមានជាយូរណាស់មកហើយអាចធូរស្រាលបាន ។*

**ស៊ុំ សាឌីណា**

# រួចពីស្លាប់ដោយសារធ្វើល្អ

គីម មានស្រុកកំណើតនៅភូមិក្រូច ឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ គីម ធ្លាប់បានរៀនអក្សរនៅវត្តគោកធ្លក បន្ទាប់មកឈប់រៀនមកជួយធ្វើការងារឪពុកម្តាយដូចជាឃ្វាលគោក្របី ដាំបាយ និងដកស្ទូងជាដើម ។

នៅឆ្នាំ១៩៧០ គីម បានចាកចេញពីឃុំកន្សោមអក ទៅធ្វើកងឈ្លបនារីនៅភូមិភាគបូព៌ា តំបន់២០៤ តាមការជ្រើសរើសរបស់យុទ្ធនារីស្រុកឈ្មោះ ស៊ីនួន ។ បន្ទាប់មក គីម ត្រូវបានបញ្ជូនទៅហាត់ក្បួនយុទ្ធសាស្ត្រនៅមន្ទីរស-២០០ ជាមួយយោធាចំនួន ១០០នាក់ទៀតនៅខាងកើតទន្លេមេគង្គ ដែលជាទីស្នាក់ការភូមិភាគក្រោមការគ្រប់គ្រងរបស់ប្រធានឈ្មោះ សាវន ។ គីម ត្រូវបានបែងចែកឲ្យទៅនៅក្នុងកងពិសេស-គ ដែលជាកងបម្រុងសម្រាប់ជួយពេលមានការប្រយុទ្ធនៅសមរភូមិមុខ ប៉ុន្តែគាត់មិនដែលបានចូលរួមប្រយុទ្ធទេ ព្រោះគាត់នៅទីស្នាក់ការតំបន់ដើម្បីជញ្ជូនស្បៀងយកទៅឲ្យកងទ័ពខាងមុខ ។

នៅដើមឆ្នាំ១៩៧៥ កងរបស់ គីម ត្រូវត្រៀមចូលប្រយុទ្ធនៅសមរភូមិអរិយក្សត្រ ។ ក្រោយពីទទួលបានជ័យជម្នះ អង្គការបានជម្លៀសប្រជាជនឲ្យទៅស្រុកកំណើតរៀងៗខ្លួនវិញ និងបានបែងចែកឲ្យកងទ័ពទាំងអស់ទៅធ្វើការនៅតាមមន្ទីរផ្សេងៗ ក្នុងក្រុងភ្នំពេញ និងតាមភូមិភាគនានា ។ ពេលនោះអង្គការបានចាត់តាំង គីម ឲ្យធ្វើការនៅរោងចក្រតម្បាញត-៤ (មុនរបប លន់ នល់ ហៅថារោងចក្រស៊ិន ហេង) ក្រោមការគ្រប់គ្រងរបស់ តារ៉ែន ប្រធាន និង ធន ជាអនុប្រធាន (បច្ចុប្បន្នរស់នៅភូមិសាសន៍ដារ ស្រុកសំពៅលូន) ដែលមានទីតាំងនៅវត្តចាក់អង្រែលើ ។ ក្រោយពីការប្រជុំបែងចែកទៅតាមមុខនាទីរៀងៗខ្លួន គីម ត្រូវចាត់តាំងឲ្យធ្វើជាប្រធានក្រុមផ្នែកអន្ទង និងរៀបចំអំបោះកុំឲ្យជំពាក់ ដែលមានសមាជិកចំនួន៣០នាក់ ។ ការងារនេះមានការលំបាកណាស់ ព្រោះប្រសិនបើធ្វើឲ្យអំបោះដាច់ច្រើន អង្គការនឹងចោទថាជាសមាសភាពក្បត់ ។ ដូច្នេះ គីម ព្យាយាមធ្វើការណាស់ ដោយគាត់មិនសូវហ៊ាននិយាយស្តីជាមួយសមាជិកនៅក្នុងក្រុមទេ ព្រោះខ្លាចជាប់ចោទថាជាខ្សែខ្មាំងបង្កប់ ។ គីម រៀបរាប់ថា «អង្គការមិនប្រាប់យើងឲ្យដឹងទេ ប៉ុន្តែអង្គការតាមដាន» ។

នៅឆ្នាំ១៩៧៦ គីម បានទទួលភារកិច្ចថ្មីបន្ថែមទៀត គឺធ្វើជាកងសន្តិសុខដើរត្រួតពិនិត្យមើលកម្មករនៅក្នុងរោងចក្រតម្បាញត-៤ ដែលមានសមាជិក១០នាក់ ។ នៅទីនេះ ក្រៅពីធ្វើការងារប្រចាំថ្ងៃ កម្មករទាំងអស់មានកាតព្វកិច្ចផ្តល់ឈាមជូនអង្គការ ដើម្បីជួយសង្គ្រោះអ្នករបួស ប្រសិនបើក្រុមណាមិនស្ម័គ្រចិត្តអង្គការនឹងរិះគន់ថា «ក្រុមអ្នកឯងគ្មានអ្នកផ្តល់ឈាមជូនជាតិជូនអង្គការ ជូនប្រជាពលរដ្ឋទេ» ។ លើសពីនេះ អង្គការលើកឡើងថាមានអ្នករបួសស៊ិតដៃនិងស៊ិតជើងជាច្រើន ហើយអ្នកខ្វះទៀតខ្វះឈាម ដូច្នេះការផ្តល់ឈាមជាការរួមចំណែកដ៏សំខាន់ដើម្បីជួយជាតិ ។ ដោយសារមិនហ៊ានប្រឆាំងនឹងអង្គការ គីម បានស្ម័គ្រចិត្តបរិច្ចាគឈាមជូនអង្គការចំនួន៤លើក ។

នៅខែធ្នូ ឆ្នាំ១៩៧៨ អង្គការបានចាប់ផ្តើមស្រាវជ្រាវរកសមាសភាពក្បត់ដើម្បីចាប់ខ្លួន ។ ពេលនោះ តាចេង អន ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម បានហៅសមាជិករោងចក្រទាំងអស់ឲ្យចូលរួមវគ្គរៀនសូត្រដោយលើកឡើងថា «បងប្អូនយួននៅជិតៗនេះ ហើយយើងអត់ដឹងថាអ្នកណាយួន អ្នកណាខ្មែរទេ ប៉ុន្តែកុំភ័យ អង្គការស្គាល់ច្បាស់» ។ ក្រោយពីប្រជុំចប់ ប្រធាននិងអនុក្រុមរោងចក្រប្រមាណ៣០នាក់ត្រូវបានអង្គការចាប់យកទៅឃុំឃាំងនៅគុកត្រពាំងក្រឡឹង ។ ចំណែក គីម ក៏ត្រូវចាប់ខ្លួនបញ្ជូនទៅទីនោះដែរ ក្រោមការគ្រប់គ្រងរបស់សមមិត្ត ប៉ើយ និងសមមិត្ត ដាំ ចែ ។ នៅទីនេះ គីម ត្រូវវាយបំបែកដុំថ្មជាមួយអ្នកទោសស្រីប្រុសនិងក្មេងៗជាច្រើន ។ ប៉ុន្តែ គីម មិនសូវទទួលរងការលំបាកទេ ព្រោះក្រៅពីការងារវាយថ្ម អង្គការមិនបានឲ្យ គីម ធ្វើការអ្វីទៀតទេ ព្រោះគាត់ធ្លាប់មានប្រវត្តិផ្តល់ឈាមជូនអង្គការ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំ គីម និងអ្នកទោសនៅគុកត្រពាំងក្រឡឹងទាំងអស់ត្រូវកងទ័ពខ្មែរក្រហមកៀរទៅព្រំដែនថៃ ។ តាមផ្លូវធ្វើដំណើរ គីម បានជួបប្រជាជនជាច្រើនដែលត្រូវ

កៀរទៅទិសខាងលិចដែរដូចជាក្មេងកំព្រា ជនពិការ និងស្ត្រីពោះធំជាដើម ហើយគ្មានអាហារបរិភោគថែមទៀត ។ ដោយសារតែមានទឹកចិត្តអាណិតអាសូរអ្នកទាំងនោះ គីម ក៏បានចែកអាហារខ្លះទៅឲ្យ ដែលភាគច្រើនជាអ្នកជម្លៀសមកពីខេត្តស្វាយរៀង ។ ពេលមកដល់វាលស្រែ១០០ ក្នុងខេត្តបាត់ដំបង ក្រុមរបស់ គីម បានចែកអង្ករមួយបាវទៅឲ្យស្ត្រី៥នាក់ដែលវង្វេងបាត់ប្តីរួមជាមួយនឹងកូនតូចៗ ។ លើសពីនេះទៅទៀត នៅថ្ងៃមួយពេលដែលក្នុងស្រុកនេះមានអាកាសធាតុត្រជាក់ខ្លាំង គីម បានឲ្យក្រុមាខោអាវ និងកៅស៊ូតង់របស់កងទ័ពដល់ប្រជាជន៦នាក់ ។

រយៈពេលមួយខែ គីម និងកងយោធាទាំងអស់បានដើរទៅដល់ទិសខាងលិចក្បែរព្រំដែនខ្មែរ-ថៃ (ដូង-ឡែម) ។ នៅទីនោះពុំមានអ៊ីហូបទេ ដូច្នេះ គីម ក៏ចូលទៅក្នុងទឹកដីថៃដើម្បីសុំអំពៅពីម្ចាស់ចម្ការមកហូប ។ ដោយសារអំពើល្អដែលគាត់បានធ្វើពីមុន ទោះជាមកដល់ទីនេះ ក៏ គីម មិនសូវពិបាកដែរ ព្រោះគាត់បានជួបអ្នកមានចិត្តសប្បុរសដូចជាតា យឿម (ដើមកំណើតខ្មែរនៅបាត់ខេត្តបាត់ដំបង) និងប្រពន្ធគាត់ឈ្មោះ យាយណាន់ (ដើមកំណើតលាវ) តែងតែផ្តល់អង្ករ ស្ករ ប៊ីចេង និងរបស់របរប្រើប្រាស់មួយចំនួនឲ្យមកដល់គាត់និងកងទ័ពជានិច្ច ។

ក្រោយមក ខ្មែរក៏ចាប់ផ្តើមមានទំនាក់ទំនងជាមួយទាហានថៃ ហើយក៏បានបានចាត់តាំង គីម ឲ្យធ្វើការនៅក្នុងកងពលលេខ១០២ដឹកស្បៀងនិងសម្ភារៈយោធាតាមច្រកព្រំដែនឡែមនិងជញ្ជូនគ្រាប់៦០មីលីម៉ែត្រ អាកា គ្រាប់បេ មីនគោន មីនស្ករបន្តយកទៅឲ្យកងទ័ពដែលប្រចាំការនៅតាមភូមិជាប់ព្រំដែននិងនៅអន្លង់មៀនខាងត្បូងបាត់ដំបងដែលត្រូវចំណាយពេលពី៧ថ្ងៃទៅ១ខែ ។ ថ្ងៃមួយពេល ដើរកាត់សមរភូមិ គីម បានប្រទះឃើញក្មេងប្រុសម្នាក់ដើរវង្វេងម្តាយ គាត់ក៏បានឲ្យពោតលីង និងទឹកមួយបំពង់ឫស្សីទៅក្មេងនោះ ។ ចំណែក ចេង សុហ៊ុន ជាមិត្តរួមការងាររបស់ គីម នៅរោងចក្រតម្បាញត-៤ ដែលមានជំងឺក្អកនិងសន្ទប់ញឹកញាប់ពេលធ្វើការងារ ត្រូវបាន គីម បញ្ជូនឲ្យទៅព្យាបាលជំងឺនៅជំរំខាវអ៊ីដាង ព្រោះគាត់គិតថា «នៅពេលចាស់នឹងមានអ្នកផ្សេងជួយគាត់វិញហើយ» ។ ក្រៅពីជួយប្រជាជន គីម ក៏បានជួយព្យាបាលជំងឺកងទ័ពដូចជាគ្រុនឈាម គ្រុនក្តៅ ដោយប្រើថ្នាំឫសឈើ ថ្នាំគ្រាប់ដែរ ។

នៅពេលត្រឡប់មកស្រុកកំណើត គីម បានជួប សុហ៊ុន ម្តងទៀត ។ ចាប់តាំងពីពេលនោះមក គាត់មិនដែលបានជួបទេ ព្រោះ សុហ៊ុន ទៅរស់នៅស្រុកត្បូងឃ្មុំ និងបានរៀបការជាមួយនឿន ។ ទោះនៅឆ្ងាយពីគ្នា ក៏ សុហ៊ុន តែងតែផ្តាំសួរសុខទុក្ខ គីម តាមរយៈបងប្រុសរបស់គាត់ដែលធ្លាប់ធ្វើការនៅរោងចក្រតម្បាញត-៥ជានិច្ច ។ នៅឆ្នាំ១៩៩២ គីម បានរៀបការនិងមានកូនម្នាក់ ។ សព្វថ្ងៃ គីម ជាសមាជិកឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។ គីម នៅតែចងចាំពាក្យម្តាយដែល តែងប្រដៅគាត់ថា «កូនអើយកូនឯងចេះជួយគេ ទោះអ្នកនោះនឹងមិនបានជួយកូនឯងក៏ដោយ ប៉ុន្តែក៏មានអ្នកផ្សេងគេនឹងជួយកូនដែរ» ។ នៅក្នុងភូមិ គីម មិនរៀនសូត្រជ្រៅជ្រះខាងវិជ្ជាពេទ្យទេ ប៉ុន្តែគាត់អាចធ្វើជាឆ្មបបង្កើតកូនឲ្យអ្នកភូមិបានដែរ ។ សព្វថ្ងៃនេះ គីម ឈប់ធ្វើឆ្មបទៀតហើយ ប៉ុន្តែគាត់នៅតែជួយអ្នកភូមិដែលមានជំងឺដដែល ។ **ហ៊ិន សុធានី**

## ដំណឹងស្វែងរកបងប្រុស

នាងខ្ញុំឈ្មោះ ប៊ុន ឡាម៉ៃ សព្វថ្ងៃរស់នៅទីក្រុងហុងកុង សូមស្វែងរកបងប្រុសឈ្មោះ ប៊ុន ឡាទោត ដែលបានបែកគ្នានៅចុងឆ្នាំ១៩៧៥ កាលពីអាយុ១៦ឆ្នាំ ក្នុងភូមិដងអៀន ស្រុកអារញ្ញប្រាថេត ខេត្តសាកែវ ប្រទេសថៃ ក្បែរព្រំប្រទល់ប្រទេសខ្មែរនៃខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ ប៊ុនឡា ប៊ុតស៊ី (នៅរស់) និងម្តាយឈ្មោះ ប៊ុន ឡាគឿ (នៅរស់) ។ នាងខ្ញុំមានបងប្អូនបួននាក់ បងទី១) ប៊ុន ឡាទោត (បាត់ខ្លួន), បងទី២) ប៊ុន ឡាអាត (នៅរស់), បងទី៣) ប៊ុន ឡាលេត (នៅរស់) និងបងទី៤) ប៊ុន ឡាឡៃ (នៅរស់) ។


ប៊ុន ឡាទោត

ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះ ប៊ុន ឡាទោត នេះ សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១២ ១៨៣៧ ៣៥៨ ដែលមានអសយដ្ឋានផ្ទះលេខ៣៩AEo ផ្លូវលេខ២៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ យើងខ្ញុំនឹងមានជូនជាសគុណ ។



ចេតិយនៅក្នុងបរិវេណព្រះបរមរាជវាំង ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



បុគ្គលិកបម្រើគណៈប្រតិភូកាលពីឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា





ស្ពានជ្រោយចង្វារដែលដាច់ដោយសារការទម្លាក់គ្រាប់បែក (ភ្នំពេញ) ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា




ទីក្រុងភ្នំពេញក្នុងខែសីហា ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ទីក្រុងភ្នំពេញដែលគ្មានមនុស្សរស់នៅ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ទីក្រុងភ្នំពេញក្នុងថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ដំណើរទស្សកិច្ចតាមទូកនៅទីក្រុងភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



លេណដ្ឋានរបស់ លន់ ណុល ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ផ្នែកមួយនៃទីប្រជុំជនស្គន់ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា


កងចល័តកុមារនិងយុវនារីចេញដំណើរទៅធ្វើការដោយជិះរថយន្តក្រុង (នៅភាគខាងជើងទីក្រុងភ្នំពេញ) ឆ្នាំ១៩៧៨
រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា


ស្ត្រីម័យកណ្ដាលធ្វើការនៅក្នុងវាលស្រែរបស់សហករណ៍ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដ


កងចល័តនារីរង់ចាំរថយន្តក្រុង (នៅចំណតសាឡាងខាងជើងទីក្រុងភ្នំពេញ)
ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា


កងចល័តកំពុងសាងសង់ទំនប់ទឹកខ្វាតតូចនៅភាគខាងជើងទីក្រុងភ្នំពេញ ឆ្នាំ១



ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



សាឡាងឆ្លងកាត់ទន្លេនៅភាគខាងជើងទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ស្ត្រីវ័យកណ្តាលធ្វើការនៅក្នុងវាលស្រែ ឆ្នាំ១៩៧៨
រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កុមារសហករណ៍ដេញចាបក្នុងស្រែ ឆ្នាំ១៩៧៨
រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា





ក្រុមគ្រួសារនេះមកពីទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ការទទួលទានបាយរួម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ការទទួលទានបាយរួម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កុមារចាប់កង្កែបនៅតាមវាលស្រែ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ការឈប់សំចតនៅតាមផ្លូវដើម្បីឱ្យគណៈប្រតិភូថតរូប និងថតវីដេអូ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



យុវនារីកំពុងធ្វើការងារនៅអតីតចំណតរថយន្តក្រុងនៅកំពង់ចាម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ដាលស្រែនៅតាមផ្លូវពីកំពង់ចាម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



រោងចក្រកែច្នៃកៅស៊ូនៅកំពង់ចាម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កម្មករនៅក្នុងរោងចក្រកែច្នៃកៅស៊ូ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កម្មករនៅក្នុងរោងចក្រកែច្នៃកៅស៊ូ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា




រោងចក្រផលិតឱសថនៅកំពង់ចាម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



រោងចក្រផលិតឱសថនៅកំពង់ចាម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



អ្នកផលិតឱសថ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ផ្ទះសំណាក់នៅក្រៅទីរួមខេត្តកំពង់ធំ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



នៅតាមផ្លូវឆ្ពោះទៅសៀមរាប ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា





ការដ្ឋានសាងសង់ទំនប់ប្រឡាយនៅតាមផ្លូវទៅទិសខាងជើង ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ការដ្ឋានសាងសង់ទំនប់ប្រឡាយ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



អ្នកធ្វើការនៅក្នុងការដ្ឋានសាងសង់ទំនប់ប្រឡាយ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



សមាជិកកងចល័តនៅការដ្ឋានសាងសង់ទំនប់ប្រឡាយ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ផ្នែកមួយនៃប្រឡាយដែលជីករួច ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កម្មកររោងចក្រនៅទីក្រុងភ្នំពេញ ផលិតឧបករណ៍កសិកម្ម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កម្មកររោងចក្រនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



សាលាបច្ចេកទេសនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



សិស្សនៅសាលាបច្ចេកទេស ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



មន្ទីរពេទ្យនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



មន្ទីរពេទ្យនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា





របាំបដិវត្តន៍នៅរោងមហោស្រពទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



សាលាបដិវត្តន៍នៅរោងមហោស្រពទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



សាលាបដិវត្តន៍នៅរោងមហោស្រពទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កម្មករតម្បាញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា




ផែកប៉ាល់នៅកំពង់សោម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



សំឡីគសម្រាប់នាំចេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ការផលិតទូកនៅក្រុងកំពង់សោម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ការផលិតទូក ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



នាវារបស់យោធាខ្មែរក្រហម ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា




ទូកនេសាទ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កុមារនៅលើនាវា ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



សហករណ៍នៅភាគអាគ្នេយ៍នៃប្រទេស ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ប្រធានសហករណ៍ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ផ្ទះបាយសហករណ៍ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



រោងជាងសហករណ៍ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ផលិតជប ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កុមារីនៅសហករណ៍ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កុមារីនិងគ្រូបង្រៀននៅសហករណ៍ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



មណ្ឌលកុមារ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



កុមារនៅភាគអាគ្នេយ៍នៃប្រទេស ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា


សង់ផ្ទះគំរូ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា


ផ្ទះគំរូ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា





សាលារៀន ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ថ្នាក់រៀន ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ថ្នាក់រៀន ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

## អនុសានុកថា

## «ដំណើរទៅកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨»

ឥឡូវនេះលោកអ្នកបានឃើញអ្វីដែលយើងបានឃើញនៅក្នុងដំណើរទស្សនកិច្ចរយៈពេលចំនួន១៤ថ្ងៃនៅប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដូចដែល ហ្គុនណា បាននិយាយរួចមកហើយនៅក្នុងសេចក្តីផ្តើម គាត់យល់ថាដំណើរទស្សនកិច្ចនោះគឺជាកំហុសធ្ងន់មួយ ពីព្រោះវាគឺជាផ្នែកមួយនៃការឃោសនានយោបាយរបស់ខ្មែរក្រហម ។

យើងមិនអាចត្រឡប់ក្រោយវិញបានទេ ។ ហ្គុនណា បានរៀនសូត្រជាច្រើនអំពីកង្វះខាតរបស់គាត់នៅក្នុងការវិនិច្ឆ័យរបបខ្មែរក្រហមកាលពីពេលនោះ ។ ប្រហែលជាគាត់អាចចែករំលែកមេរៀនប្រវត្តិសាស្ត្រមួយចំនួនជាមួយអ្នកដទៃដើម្បីកុំឲ្យមានរឿងបែបនេះកើតឡើងម្តងទៀត ។ ប្រហែលជាមានមេរៀនប្រវត្តិសាស្ត្រមួយចំនួនទៀតដែលគាត់មិនទាន់យល់ច្បាស់ ហើយលោកអ្នកអាចមើលឃើញថាគាត់មិនទាន់អាចធ្វើសេចក្តីសន្និដ្ឋានបាននៅឡើយ ។

បទពិសោធន៍របស់ ហ្គុនណា បានបង្រៀនគាត់ថា សិទ្ធិជាមូលដ្ឋានមួយចំនួនរបស់មនុស្សមិនអាចលុបបំបាត់បានទេគឺ ÷

- សិទ្ធិក្នុងការគិតនិងបញ្ចេញមតិយោបល់
- សិទ្ធិក្នុងការគោរពនិងប្រតិបត្តិសាសនាណាមួយ
- សិទ្ធិក្នុងការធ្វើដំណើរ

ហ្គុនណា ក៏សង្ឃឹមដែរថា គាត់បានប្រែក្លាយទៅជាមនុស្សដែលមានការសង្ស័យខ្លះចំពោះពាក្យដែលថា «អ្វីៗទាំងអស់ត្រូវបានដោះស្រាយ» ចំពោះមេដឹកនាំដែលអះអាងថាខ្លួនបានមើលឃើញការពិតគ្រប់យ៉ាងនិងចំពោះការអះអាងដែលថាអាចដោះស្រាយគ្រប់បញ្ហាបានយ៉ាងឆាប់រហ័ស ។

ហ្គុនណា នៅតែមានជំនឿចិត្តថាយើងនឹងមានពិភពលោកមួយដែលស្មើភាពនិងយុត្តិធម៌សម្រាប់មនុស្សទាំងអស់គ្នាប្រសើរជាងពិភពលោកដែលយើងកំពុងតែរស់នៅសព្វថ្ងៃ ។

ហ្គុនណា សូមខមាទោសចំពោះអ្នកដែលទទួលរងការប៉ះទង្គិចដោយសារតែការគាំទ្ររបស់គាត់ចំពោះខ្មែរក្រហម និងជាពិសេសចំពោះអ្នកដែលរងគ្រោះដោយផ្ទាល់នៅក្រោមរបបនោះ ។

**ហ្គុនណា ប៊ើយស្ត្រម**



រោងចក្រនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

# អតីតកាលរបស់ខ្ញុំ

ខ្ញុំបាទឈ្មោះ រស់ វិបុល សព្វថ្ងៃរស់នៅបន្ទាយ១០ ខេត្តព្រៃវែង ឪពុកឈ្មោះ រស់ រ៉េត ហៅ ភេម មុត ធ្វើជាទាហាន លន់ នល់ និងម្ដាយឈ្មោះ ស្រ៊ុន យ៉ែម សព្វថ្ងៃរស់នៅភូមិក្បាលជ្រោយ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្ដាល ។

ចុងឆ្នាំ១៩៧៦ បងៗទាំងអស់របស់ខ្ញុំរស់នៅជាមួយឪពុកខ្ញុំនៅទីរួមខេត្តព្រៃវែង ចំណែកខ្ញុំរស់នៅជាមួយម្ដាយនៅភូមិទួលលាន ស្រុកព្រះស្ដេច ខេត្តព្រៃវែង ។ បន្ទាប់ពីឪពុកខ្ញុំស្លាប់ទៅ បងទាំងបីនាក់របស់ខ្ញុំក៏បានត្រឡប់មករស់នៅជុំគ្នាជាមួយម្ដាយខ្ញុំវិញ ។ ក្រោយមក ម្ដាយខ្ញុំបានផ្លាស់មករស់នៅមកនៅស្រុកកំណើតរបស់គាត់ក្នុងភូមិជំរៅ ឃុំកំពង់សឹង ស្រុកព្រះស្ដេច ខេត្តព្រៃវែងវិញ ។ នៅទីនោះ អង្គការចាត់ទុកគ្រួសារខ្ញុំជាអ្នក១៧មេសា ព្រោះគ្រួសារខ្ញុំជាប្រជាជនថ្មី ។ លើសពីនេះទៅទៀត ម្ដាយរបស់ខ្ញុំត្រូវអង្គការហៅឲ្យទៅចូលរួមស្ដាប់ការប្រជុំនៅក្នុងបរិវេណវត្តព្រៃច្បារដែលរៀបចំឡើងក្នុងគោលបំណងឲ្យស្ត្រីមេម៉ាយៗដែលមានប្ដីធ្វើទាហានក្នុងរបប លន់ នល់ ធ្វើការប្ដេជ្ញាចិត្តនិងនិយាយការពិតប្រាប់គណៈតំបន់ ។ ដោយជឿជាក់លើការឃោសនាថាអង្គការនឹងមិនយកទោសពៃរ៍ ម្ដាយខ្ញុំក៏បានរៀបរាប់ការពិតដោយគ្មានលាក់លៀមអ្វីឡើយ ។ មួយខែក្រោយមក ស្រាប់តែក្រុមគ្រួសារខ្ញុំត្រូវបានអង្គការកត់ឈ្មោះ រួចប្រាប់ឲ្យធ្វើដំណើរទៅអ្នកលឿង ។ នៅពេលកំពុងរង់ចាំរថយន្តមកដឹក ខ្ញុំបានឃើញប្អូនជីដូនមួយរបស់ម្ដាយខ្ញុំស្លៀកពាក់អាវទាហានមានស្ពាយសាក់កាដូនិងកាំភ្លើងចុះពីលើរថយន្តដើរសំដៅមករកម្ដាយរបស់ខ្ញុំ ហើយសួរថាបងទៅណា? ម្ដាយខ្ញុំប្រាប់គាត់ថាអង្គការឲ្យទៅរស់នៅដីខ្លាញ់ ហើយក្រុមគ្រួសាររបស់ប្អូនក៏មានឈ្មោះទៅដែរ ។ គ្រាន់តែឮពាក្យនេះគាត់បានលាម្ដាយខ្ញុំត្រឡប់មកភូមិជាប្រញាប់ដើម្បីធានាក្រុមគ្រួសាររបស់គាត់ឲ្យរស់នៅក្នុងភូមិដដែល ។


ជា វិបុល ថតជាមួយម្ដាយនៅវត្តសុវណ្ណរង្សី ខេត្តព្រៃវែង នៅឆ្នាំ១៩៨៨

នៅពេលដែលគ្រួសារខ្ញុំមកដល់អ្នកលឿងបានមួយសន្ទុះ ខ្ញុំក៏ឃើញរថយន្តជាច្រើនគ្រឿងដឹកប្រជាជនមកពីខេត្តស្វាយរៀង ព្រៃវែង និងកំពង់ចាមមកដល់ទីនេះដែរ ។ ក្រោយពីធ្វើដំណើរជាច្រើនថ្ងៃតាមកប៉ាល់និងរថភ្លើង នៅម៉ោង១២យប់ គ្រួសាររបស់ខ្ញុំក៏បានមកដល់ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ខ្មែរក្រហមមិនបានឲ្យគ្រួសាររបស់ខ្ញុំឈប់សម្រាកទេ ដោយឲ្យបន្តដំណើរទាំងយប់ទៀត រហូតមកដល់ខ្នងទំនប់១៧មេសា ។ ព្រឹកឡើង អង្គការបញ្ជូនម្ដាយខ្ញុំទៅរស់ទៅភូមិអូសទូក ឃុំផ្ទះរុង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។ នៅទីនោះ អង្គការបានប្រមូលប្រជាជនដែលទើបនឹងជម្លៀសមកឲ្យចូលរួមស្ដាប់អង្គប្រជុំណែនាំពីផែនការរបស់ថ្នាក់លើដាក់ឲ្យធ្វើ ។ ចំណែកខ្ញុំត្រូវបានអង្គការបំបែកឲ្យទៅធ្វើការនៅក្នុងកងចល័តកុមារមានគ្នា២០នាក់ ដោយស្នាក់នៅក្នុងផ្ទះមួយសង់ពីឈើប្រក់ស្បូវមានបណ្ដោយ៧ម៉ែត្រ និងទទឹង៦ម៉ែត្រ ។ ខ្ញុំត្រូវដេកផ្ទាល់ដីនៅក្នុងរោងគ្មានជញ្ជាំង មានតែក្រមាមួយនិងសម្លៀកបំពាក់មួយកំប្លេប៉ុណ្ណោះ ។ បន្ទាប់មកអង្គការចាត់តាំងឲ្យលោកគ្រូម្នាក់ដែលជាអ្នកមូលដ្ឋានមកបង្រៀនខ្ញុំ និងក្មេងមូលដ្ឋាន ម្នាក់ទៀតឲ្យធ្វើជាមេកងសម្រាប់ដឹកនាំក្រុមកុមារ ។

ពេលនោះ ខ្ញុំត្រូវដើររើសអាចម៍គោនិងអាចម៍ក្របីនៅពេលព្រឹក និងពេលល្ងាចទៅកាប់ដើមទន្ទ្រានខែត្រ ព្រមទាំងបំបែកដីដំបូក យកមកបុកចិញ្ច្រាំលាយធ្វើជីដាក់ស្រែ ប៉ុន្តែថ្ងៃខ្លះ ដោយសារខ្ញុំធ្វើការមិនបានតាមផែនការកំណត់ ខ្ញុំក៏ត្រូវលោកគ្រូធ្វើទារុណកម្ម ដោយចាប់មួលកដៃ និងញ៉ីងស្លឹកត្រចៀកដែរ ។ ក្រោយមក អង្គការដាក់ផែនការឲ្យខ្ញុំនិងកុមារ៣នាក់ទៀតជីកប្រឡាយទំហំ ១ម៉ែត្រគារ៉េឲ្យហើយក្នុងរយៈពេល១ថ្ងៃ ។ ពេលនោះ ស្រាប់តែផ្លែចបរបស់កុមារម្នាក់របូតធ្លាក់ចំក្បាលខ្ញុំបណ្តាលឲ្យហូរឈាមយ៉ាងខ្លាំង ។ ទោះយ៉ាងនេះក្តី ប្រធានកងមិនឲ្យខ្ញុំឈប់សម្រាកទេ ដោយគាត់គ្រាន់តែទំពាស្មៅយកមកបិទមុខរបួស រួចបញ្ជាឲ្យខ្ញុំធ្វើការបន្តទៀត ។ ដោយសារធ្វើពលកម្មធ្ងន់ធ្ងរស្ទើរគ្មានពេលសម្រាកនិងគ្មានអាហារហូបគ្រប់គ្រាន់ បណ្តាលឲ្យកុមារនៅក្នុងកងធ្លាក់ខ្លួនឈឺនិងស្លាប់ជាបន្តបន្ទាប់ ។ នៅពេលនោះ ម្តាយខ្ញុំតែងតែលួចយកបាយឬបបរ ដែលជាចំណែករបស់គាត់មកឲ្យខ្ញុំហូបជារៀងរាល់ថ្ងៃ ។ ប៉ុន្តែខ្ញុំនៅតែធ្លាក់ខ្លួនឈឺហើមដដែល ។ ព្រោះតែខ្លាចខ្ញុំឈឺរហូតដល់ស្លាប់ដូចក្មេងដទៃ ម្តាយខ្ញុំក៏បានទៅសុំអង្គការយកខ្ញុំទៅព្យាបាលនៅកងរបស់គាត់វិញ ។ នៅទីនោះ កងនារីបានប្រាប់ឲ្យម្តាយខ្ញុំយកល្ហុងខ្ចីមកខ្ទៀលយកគ្រាប់ចេញ រួចយកកន្ទុកមកលាយជាមួយស្ករពាង ហើយញាត់បញ្ចូលទៅក្នុងផ្លែល្ហុង បន្ទាប់មកស្ងោរឲ្យឆ្អិនឲ្យខ្ញុំហូបម្តងមួយជ្រុងៗ ។ ក្រោយពីហូបរួច ជំងឺហើមរបស់ខ្ញុំចាប់ផ្តើមស្រក ហើយជាសះស្បើយរហូតមកដល់សព្វថ្ងៃនេះ ។ មិនយូរប៉ុន្មាន ម្តាយរបស់ខ្ញុំក៏ត្រូវអង្គការចោទថាជាយួននិងបានហៅគាត់ទៅសាកសួរជាច្រើនលើក ព្រោះតែគាត់មានសម្បុរ-សនិងមានមាឌតូចល្អិត ។ ចំណែកម្តាយខ្ញុំឆ្លើយថា «ខ្ញុំជាកូនខ្មែរ ប៉ុន្តែមានជីតាជាប់ខ្សែស្រលាយចិន» ។ ខ្មែរក្រហមនៅតែមិនអស់ចិត្តទេដោយបានហៅបងស្រីខ្ញុំសួរទៀត តែសំណាងល្អ ដោយបងស្រីខ្ញុំមានសម្បុរស្រអែម ទើបអង្គការលែងចោទប្រកាន់គាត់ ប៉ុន្តែគ្រួសារខ្ញុំស្ថិតក្នុងតាមដានដដែល ។ ចំណែកបងប្រុសខ្ញុំពីរនាក់ដែលធ្វើការនៅលើភ្នំក្រវាញត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល ពេលគាត់សុំច្បាប់ត្រឡប់មកលេងផ្ទះនិងបងប្រុសខ្ញុំម្នាក់ទៀតដែលធ្វើការនៅកងចល័តក៏ត្រូវអង្គការតាមដានជាប្រចាំដែរ ដោយសារគាត់មានចរិតរបិលរប៉ូច ធ្លាប់កុហកអង្គការនិងលួចរត់មកលេងម្តាយញឹកញាប់ ។ ថ្ងៃមួយពេលគាត់សុំច្បាប់ប្រធានកងចល័តសម្រាកមួយថ្ងៃដោយសារគាត់វិលមុខខ្លាំងពេក ស្រាប់តែប្រធានកងនោះបដិសេធ ហើយថែមទាំងចោទថាឈឺពុត រួចគំរាមថា «ខ្យល់អ្លែងទុកឲ្យអញកោស» រួចក៏ចាប់បងខ្ញុំសង្កត់ ដោយយកស្លាបព្រាហូបបាយមកកោសជាមួយនឹងទឹក រហូតដាច់ស្បែកហូរឈាមពេញខ្លួន ។ បន្ទាប់ពីរើបម្រះរួច បងប្រុសខ្ញុំបានលួចរត់មករកម្តាយនៅផ្ទះវិញ ។ មួយរយៈក្រោយមក គាត់ក៏ត្រូវប្រធានកងចល័តចាប់ចងឲ្យរត់តាមពីក្រោយសេះរហូតដាច់ខ្យល់ស្លាប់ ។

ចុងឆ្នាំ១៩៧៨ នៅពេលខ្ញុំដឹកជញ្ជូនស្រូវយកមកទុកក្នុងព្រៃ ខ្ញុំបានឃើញរណ្តៅសាកសពជាច្រើន ដោយមានឆ្អឹងខ្មោចខ្លះត្រូវឆ្កែចចកអូសទាញយកមកហែកស៊ីនិងខោអាវអ្នកដែលត្រូវសម្លាប់នៅព្យួររណែងរណោងពេញព្រៃ ។ មិនយូរប៉ុន្មាន ពេលដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមករំដោះ ខ្មែរក្រហមក៏រត់ភៀសខ្លួនឡើងភ្នំរួចបន្តឆ្លងចូលទឹកដីថៃ ចំណែកប្រជាជនខ្លះក៏ត្រឡប់មកលំនៅឋានរៀងៗខ្លួនវិញដែរ ។ នៅពេលនោះ ស្រាប់តែមានកងទ័ពវៀតណាមធ្វើសញ្ញាឲ្យប្រជាជនរកកន្លែងពួន ។ ខ្ញុំភិតភ័យខ្លាំងណាស់ក៏ប្រញាប់ប្រញាល់រត់ទៅឱបម្តាយខ្ញុំ រួចខ្ញុំធ្វើបានរទេះអូសមួយសម្រាប់ដាក់អង្ករចានឆ្នាំង ដែលប្រមូលបានធ្វើដំណើរមកកាន់ទីប្រជុំជនលាជ ។ តាមផ្លូវខ្ញុំឃើញរោងឈើមួយយ៉ាងធំវែង និងមានប្រជាជនខ្លះយកដុំថ្ម ដុំដីកំណាត់ឈើគប់ចូលទៅក្នុងរោងនោះ ។ ខ្ញុំអើតមើលឃើញមនុស្សប្រុសស្រីប្រមាណ១០នាក់ ដែលជាមេកង មេក្រុម មេតំបន់ត្រូវបានកងទ័ពរណសិរ្សចាប់ចង ។

ទោះជាមិនសូវមានកម្លាំងក៏ដោយ ក៏ខ្ញុំខំប្រឹងធ្វើដំណើរត្រឡប់មកស្រុកកំណើតដើម្បីជួបជុំបងប្អូននិងញាតិសន្តានវិញដែរ ។ ស្នាក់នៅលាជបានមួយរយៈ កងទ័ពវៀតណាមបានឲ្យគ្រួសារខ្ញុំជិះរថយន្តរបស់កងទ័ពមកកាន់ខេត្តពោធិ៍សាត់ រួចបន្តដំណើរទៅភូមិក្បាលជ្រោយ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ។ នៅឆ្នាំ១៩៨៨ ខ្ញុំបានផ្ទេរការសិក្សាពីសាលាមធ្យមសិក្សាកំពង់ភ្នំទៅសាលាមធ្យមសិក្សាព្រៃវែងក្រុងវិញ ។ ក្រោយពីប្រឡងបាក់ឌុបបាន៣ឆ្នាំ ខ្ញុំក៏បានរៀបអាពាហ៍ពិពាហ៍និងរស់នៅក្នុងទីរួមខេត្តព្រៃវែងរហូតមកដល់សព្វថ្ងៃ ។ **ឌា ទិបុល**

## ការដ្ឋានសាងសង់ទំនប់ប្រឡាយ ឆ្នាំ១៩៧៨ រក្សាសិទ្ធិដោយមជ្ឈមណ្ឌលឯកសារកម្ពុជា



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Special Number 107, November 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.